# ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូល

## ថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025

**សេចក្តីណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតផ្លូវការ**

### កុំពន្យារពេល សូមបោះឆ្នោតនៅថ្ងៃនេះ!

រយៈពេលបោះឆ្នោតតាមសំបុត្រជាមុនគឺចាប់ពីថ្ងៃទី 6 ខែតុលា ដល់ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។

ការបោះឆ្នោតចាប់បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025 ជាថ្ងៃបោះឆ្នោត!

### CALIFORNIA ព័ត៌មានដែលគួឱ្យទុកចិត្ត

អ្នកចុះឈ្មោះបោះឆ្នោតនីមួយៗនៅក្នុងរដ្ឋ California នឹងទទួលសន្លឹកបោះឆ្នោតតាមសំបុត្រ។

សន្លឹកឆ្នោតតាមសំបុត្រត្រូវបានផ្ញើនៅ ឬមុនថ្ងៃទី 6 ខែតុលា។

សន្លឹកឆ្នោតតាមសំបុត្រអាចត្រូវបានបោះឆ្នោត និងប្រគល់មកវិញភ្លាមៗនៅពេលបានទទួល។

ប្រអប់ទម្លាក់សន្លឹកឆ្នោតតាមសំបុត្រត្រូវបើកនៅថ្ងៃទី 7 ខែតុលា។

ជម្រើសបោះឆ្នោតដោយផ្ទាល់នឹងមាននៅគ្រប់ខោនធីទាំងអស់។



ប្រើតាមទូរសព្ទចល័តបាន ស្កេនខ្ញុំ

### លិខិតបញ្ជាក់ភាពត្រឹមត្រូវ

ខ្ញុំ Shirley N. Weber រដ្ឋលេខាធិការនៃរដ្ឋ California សូមបញ្ជាក់នៅក្នុងលិខិតនេះថា ព័ត៌មានដែលបញ្ចូលក្នុងលិខិតនេះនឹងត្រូវបានដាក់ជូនអ្នកបោះឆ្នោតនៃរដ្ឋ California នៅឯការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូលដែលនឹងត្រូវបានប្រព្រឹត្តទៅនៅទូទាំងរដ្ឋ នៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025 ហើយថា មគ្គុទ្ទេសក៍នេះត្រូវបានរៀបចំយ៉ាងត្រឹមត្រូវដោយអនុលោមតាមច្បាប់។ មានរូបខ្ញុំជាសាក្សី និងត្រាធំរដ្ឋនៅ Sacramento រដ្ឋ California ថ្ងៃទី 17 ខែកញ្ញា ឆ្នាំ 2025។

Shirley N. Weber, Ph.D.
រដ្ឋលេខាធិការ

# កម្រងសិទ្ធិ

## នៃអ្នកបោះឆ្នោត

---

### អ្នកមានសិទ្ធិនៅខាងក្រោម ៖

1. **សិទ្ធិដើម្បីបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនអ្នក៖
   - ជាពលរដ្ឋអាមេរិក កំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា
   - មានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ
   - បានចុះឈ្មោះនៅកន្លែងដែលអ្នករស់នៅបច្ចុប្បន្ន
   - បច្ចុប្បន្នមិនបម្រើរដ្ឋឬជាប់ពន្ធនាគារសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋមួយ,និង
   - នៅពេលបច្ចុប្បន្ននោះ មិនបានរកឃើញដោយតុលាការថាអសមត្ថភាពផ្លូវចិត្ត ដើម្បីបោះឆ្នោតឡើយ

2. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ សូម្បីតែឈ្មោះរបស់អ្នកមិននៅក្នុងបញ្ជីក៏ដោយ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន ។ ការបោះឆ្នោតរបស់អ្នកនឹងត្រូវបានរាប់ ប្រសិនបើមន្ត្រីរៀបចំការបោះឆ្នោតកំណត់ថាអ្នកមានសិទ្ធិបោះឆ្នោត ។

3. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកនៅតែឈរក្នុងជួរនៅពេលកន្លែងបោះឆ្នោតបិទ។**

4. **សិទ្ធិដើម្បីបោះសន្លឹកឆ្នោតសំងាត់** ដោយគ្មានអ្នកណាម្នាក់រំខានដល់អ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិដើម្បីទទួលសន្លឹកឆ្នោតថ្មី បើអ្នកបានធ្វើដោយភាន់ច្រឡំ** បើអ្នកមិនទាន់បានបោះសន្លឹកឆ្នោតរបស់អ្នកនៅឡើយ។ អ្នកអាច ៖

   **ស្នើសុំមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោតត** នូវសន្លឹកឆ្នោតថ្មី,
   **ដូរសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្ររបស់អ្នក សំរាប់សន្លឹកឆ្នោតថ្មី** នៅឯការិយាល័យបោះឆ្នោត ឬនៅឯកន្លែងបោះឆ្នោតរបស់អ្នក, ឬ
   **បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។**

6. **សិទ្ធិដើម្បីទទួលជំនួយ ក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីជនណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬអ្នកតំណាងសហជីពរបស់អ្នក។

7. **សិទ្ធិដើម្បីប្រគល់សន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ របស់អ្នក ដែលបានបំពេញនៅកន្លែងបោះឆ្នោតណាមួយ**ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

8. **សិទ្ធិដើម្បីទទួលសំភារៈការបោះឆ្នោត ជាភាសាមួយក្រៅពីអង់គ្លេស** បើមានប្រជាជនគ្រប់គ្រាន់នៅក្នុងតំបន់បោះឆ្នោតរបស់អ្នក និយាយភាសានោះ។

9. **សិទ្ធិដើម្បីសួរសំណួរទៅមន្ត្រីបោះឆ្នោត អំពីទំរង់ការបោះឆ្នោត** និងឃ្លាំមើលដំណើរការបោះឆ្នោត។ បើមនុស្សដែលអ្នកសួរ មិនអាចឆ្លើយសំណួររបស់អ្នកបានទេ គេត្រូវតែបញ្ជូនអ្នកទៅមនុស្សត្រឹមត្រូវដែលអាចឆ្លើយសំណួរបាន។ បើអ្នកមានឬកពាអុកឡុក គេអាចឈប់ឆ្លើយសំណួរអ្នក។

10. **សិទ្ធិដើម្បីរាយការណ៍សកម្មភាពខុសច្បាប់អ្វីមួយ ឬការបោះឆ្នោតដោយគែបន្លំ** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។

    - គេហ៍ទំព័រ នៅ **www.sos.ca.gov**
    - តាមទូរស័ព្ទ លេខ **(888) 345-4917**
    - តាមអ៊ីមែល **elections@sos.ca.gov**

---

**បើអ្នកជឿថាអ្នកត្រូវបានបដិសេធនូវសិទ្ធិណាមួយទាំងនេះ** ទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃជាសំងាត់ **(888) 345-4917**។

---

# តារាងមាតិកា

ទំព័រ

**មគ្គុទេសក៍យោងសង្ខេបរហ័ស** 5

**សំណើ**

50 អនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាបណ្តោះអាសន្នលើផែនទីតំបន់តំណាងសភា ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់សារឡើងវិញរបស់រដ្ឋ Texas តាមផ្អែកលើគណបក្ស។ ការកែប្រែរដ្ឋធម្មនុញ្ញដោយសភានីតិបញ្ញត្តិ។ ........ 8

**អត្ថបទនៃច្បាប់ដែលបានស្នើឡើង** 18

**ព័ត៌មានអ្នកបោះឆ្នោត**

កម្រងសិទ្ធិ នៃអ្នកបោះឆ្នោត........ 2
អ្នករួមវិភាគទានកំពូល........ 3
ធនធានវិបសាយថ៍រដ្ឋលេខាធិការ........ 3
សាររបស់រដ្ឋលេខាធិការ ........ 4
ព័ត៌មានថ្ងៃបោះឆ្នោត........ 5
ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក........ 5
លទ្ធផលបោះឆ្នោត........ 5
ថ្ងៃកាន់តែច្រើន វិធីច្រើនទៀតដើម្បីបោះឆ្នោតជាមួយ VCA........ 6
កុំពន្យាពេល បោះឆ្នោតថ្ងៃនេះ!........ 7
តាមដានសន្លឹកឆ្នោតរបស់អ្នក........ 7
គន្លឹះសម្រាប់ទាហាន និងអ្នកបោះឆ្នោតនៅក្រៅប្រទេស........ 19
សេចក្តីជូនដំណឹងអំពីធ្វើការអោយអ្នកឈរឈ្មោះបោះឆ្នោត........ 20
សេចក្តីជូនដំណឹងអំពីអំពើពុករលួយក្នុងដំណើរការបោះឆ្នោត........ 21
ប្រភពព័ត៌មានដែលគួរឱ្យទុកចិត្ត........ 22
ការការពារសុវត្ថិភាពការបោះឆ្នោត........ 22
លក្ខខណ្ឌតម្រូវនៃការចុះឈ្មោះ និង ID អ្នកបោះឆ្នោតនៅរដ្ឋ California... 23
សិទ្ធិបោះឆ្នោតត្រូវបានស្តារឡើងវិញ........ 24
បម្រើជាបុគ្គលិកបោះឆ្នោត........ 24
ជាអ្នកបោះឆ្នោតថ្មីមែនទេ?........ 25
អ្នកបោះឆ្នោតម៉ូតូរដ្ឋ California ........ 26
ព័ត៌មានឯកជនភាពការចុះឈ្មោះអ្នកបោះឆ្នោត........ 26
ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព........ 27
ការិយាល័យបោះឆ្នោតប្រចាំខោនធី........ 28
ពិនិត្យស្ថានភាពអ្នកបោះឆ្នោតរបស់អ្នកតាមអ៊ីនធឺណិត........ 29
ការបោះឆ្នោតបណ្តោះអាសន្ន........ 29
របៀបដោះស្រាយហត្ថលេខាដែលបាត់ ឬខុសគ្នានៅក្នុងស្រោមសំបុត្រប្រគល់សន្លឹកឆ្នោត........ 30
កាលបរិច្ឆេទដែលត្រូវចងចាំ........ 31

# អ្នកចូលរួមវិភាគទានកំពូលដល់បេក្ខជនរដ្ឋ និងវិធានការសន្លឹកឆ្នោត

នៅពេលដែលគណៈកម្មាធិការ (បុគ្គល ឬក្រុមមនុស្សដែលទទួល ឬចំណាយប្រាក់សម្រាប់គោលបំណងមានឥទ្ធិពលលើអ្នកបោះឆ្នោតដើម្បីគាំទ្រ ឬប្រឆាំងបេក្ខជន ឬវិធានការបោះឆ្នោត) រៃអង្គាសប្រាក់បានយ៉ាងហោចណាស់ $1 លានដុល្លារ នោះ ត្រូវតែរាយការណ៍ពីអ្នកចូលវិភាគទានកំពូលទាំង 10 របស់ខ្លួនទៅកាន់គណៈកម្មការអនុវត្តនយោបាយដោយយុត្តិធម៌នៃរដ្ឋ California (FPPC) ។ គណៈកម្មាធិការនេះ ត្រូវតែធ្វើបច្ចុប្បន្នភាពបញ្ជីនៅពេលមានការផ្លាស់ប្តូរណាមួយ។

បញ្ជីទាំងនេះមាននៅលើគេហទំព័រ FPPC តាម៖
*fppc.ca.gov/transparency/top-contributors.html*

ដើម្បីស្រាវជ្រាវការចូលរួមវិភាគទានក្នុងយុទ្ធនាការសម្រាប់បេក្ខជន ឬវិធានការបោះឆ្នោត សូមចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការតាមរយៈ *powersearch.sos.ca.gov*។

# សូមចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការ ដើម្បី៖

- ការរួមចំណែកក្នុងយុទ្ធនាការស្រាវជ្រាវ និងសកម្មភាពបញ្ចុះបញ្ចូល *cal-access.sos.ca.gov* ឬ *powersearch.sos.ca.gov*
- មើលការណែនាំអ្នកបោះឆ្នោតនេះជាភាសានានា *voterguide.sos.ca.gov*
- ពិនិត្យស្ថានភាពចុះឈ្មោះ និងព័ត៌មានចុះឈ្មោះរបស់អ្នក *voterstatus.sos.ca.gov*
- ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ឬមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោត *sos.ca.gov/elections/polling-place* ឬ *voterstatus.sos.ca.gov*
- ទទួលបានព័ត៌មានអំពីសន្លឹកបោះឆ្នោតតាមសំបុត្រ *sos.ca.gov/elections/voter-registration/vote-mail*
- អានព័ត៌មានមានប្រយោជន៍សម្រាប់អ្នកបោះឆ្នោតលើកដំបូង *sos.ca.gov/elections/voting-resources/voting-california*
- មើលលទ្ធផលបោះឆ្នោតផ្ទាល់ បន្ទាប់ពីការបោះឆ្នោតបិទបញ្ចប់នៅថ្ងៃបោះឆ្នោត *electionresults.sos.ca.gov*

# សាររបស់រដ្ឋលេខាធិការ

អ្នកបោះឆ្នោត California ជាទីគោរព!

ការចូលរួមរបស់អ្នកនៅក្នុងដំណើរការបោះឆ្នោតនីមួយៗមានសារៈសំខាន់ណាស់ ដើម្បីធានាដល់ការរីកចម្រើនតាមបែបលទ្ធិប្រជាធិបតេយ្យ។ ក្នុងនាមជាអ្នកបោះឆ្នោតនៅរដ្ឋ California អ្នកនឹងមានឱកាសបោះឆ្នោតនៅក្នុង**ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូល**នាពេលខាងមុខនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ ការបោះឆ្នោតនេះនឹងស្នើសុំឱ្យអ្នក**យល់ព្រម ឬបដិសេធ**សំណើបោះឆ្នោត។

អ្នកមានវិធីជាច្រើនក្នុងការចូលរួម ខណៈដែលរដ្ឋ California បន្តការពារ និងពង្រីកសិទ្ធិបោះឆ្នោតរបស់អ្នក។ យើងលើកកម្ពស់ការបោះឆ្នោតតាមសំបុត្រ មធ្យោបាយបោះឆ្នោតដោយផ្ទាល់ជាច្រើន ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ និងការបោះឆ្នោតបណ្ដោះអាសន្ន ដែលទាំងអស់នេះត្រូវបានរៀបចំឡើងដើម្បីការពារ និងបង្កលក្ខណៈងាយស្រួលដល់ការបោះឆ្នោត។

មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតនេះត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកធ្វើការសម្រេចចិត្តឱ្យបានគ្រប់ជ្រុងជ្រោយលើសំណើទី 50។ នៅក្នុងមគ្គុទ្ទេសក៍នេះ អ្នកនឹងរកឃើញព័ត៌មានលម្អិតសំខាន់ៗអំពីពេលវេលា ទីកន្លែង និងរបៀបគូសសន្លឹកឆ្នោតរបស់អ្នក ព្រមទាំងសេចក្តីសង្ខេបខ្លះៗ និងការវិភាគអំពីវិធានការ។ មគ្គុទ្ទេសក៍នេះបង្ហាញពីទឡ្ហីករណ៍ផ្លូវការដែលគាំទ្រ និងប្រឆាំងនឹងសំណើទី 50 រួមជាមួយការបដិសេធ ដើម្បីឱ្យអ្នកអាចពិចារណាលើទស្សនៈជាច្រើន មុនពេលធ្វើការសម្រេចចិត្ត។

**មគ្គុទ្ទេសក៍របស់អ្នករួមបញ្ចូល៖**

- សេចក្តីសង្ខេបឯករាជ្យអំពីសំណើទី 50 ជាមួយនឹងទឡ្ហីករណ៍គាំទ្រ និងប្រឆាំង រួមទាំងព័ត៌មានទំនាក់ទំនងសម្រាប់អ្នកគាំទ្រ និងអ្នកប្រឆាំង។ (ទំព័រទី 5)

- ការណែនាំច្បាស់លាស់អំពីរបៀបបោះឆ្នោតតាមសំបុត្រ ដោយផ្ទាល់ ឬតាមរយៈប្រអប់ទម្លាក់សន្លឹកឆ្នោតសុវត្ថិភាព។ បន្ថែមពីនេះ សូមចងចាំចុះហត្ថលេខា និងបោះត្រាលើសន្លឹកឆ្នោតរបស់អ្នក។ (ទំព័រទី 7)

- ព័ត៌មានទាក់ទងនឹងការជូនដំណឹងអំពី**សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា**តាមរយៈ *WheresMyBallot.sos.ca.gov*។

- ព័ត៌មានលម្អិតអំពីថ្ងៃបោះឆ្នោតបន្ថែម និងមណ្ឌលបោះឆ្នោតនៅក្នុងខោនធីតាមច្បាប់នៃជម្រើសរបស់អ្នកបោះឆ្នោតដែលអ្នកអាចចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃតែមួយបាន។ (ទំព័រទី 6)

ការចូលរួមក្នុងការបោះឆ្នោតគឺមានសារៈសំខាន់ ដើម្បីបញ្ចេញមតិចំពោះការសម្រេចចិត្តដែលមានឥទ្ធិពលមកលើជីវិតរបស់យើង និងរបៀបដែលសហគមន៍របស់យើងដំណើរការ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកចំណាយពេលស្វែងយល់អំពីបញ្ហា និងឥទ្ធិពលនៃការបោះឆ្នោតនេះ ហើយបន្ទាប់មកធ្វើការសម្រេចចិត្ត។ ការបោះឆ្នោតមានន័យថា សំឡេងរបស់អ្នកនឹងត្រូវបានគេឮ ហើយអ្នកមានសិទ្ធិបញ្ចេញមតិនាពេលអនាគត។

សូមអរគុណចំពោះការរក្សាលទ្ធិប្រជាធិបតេយ្យរបស់យើងឱ្យបានរឹងមាំ!

# មគ្គុទ្ទេសក៍យោងសង្ខេបរហ័ស

**សំណើ 50** **អនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាបណ្តោះអាសន្នលើផែនទីតំបន់តំណាងសភា ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់ សារឡើងវិញរបស់រដ្ឋ TEXAS តាមផ្អែកលើគណបក្ស។ ការកែប្រែរដ្ឋធម្មនុញ្ញដោយសភានីតិបញ្ញត្តិ។**

សេចក្តីសង្ខេប *ដាក់លើសន្លឹកឆ្នោតដោយអង្គនីតិបញ្ញតិ*

តម្រូវឲ្យប្រើផែនទីតំបន់តំណាងសភាថ្មីជាបណ្តោះអាសន្នរហូតដល់ឆ្នាំ 2030។ បញ្ជាឲ្យគណៈកម្មការបែងចែកតំបន់ឯករាជ្យរបស់ពលរដ្ឋបន្ត អនុម័តផែនទីតំបន់តំណាងសភាឡើងវិញក្នុងឆ្នាំ 2031។ បង្កើតគោលនយោបាយគាំទ្រគណៈកម្មការបែងចែកតំបន់សារឡើងវិញ តំណាងសភាដែលមិនផ្អែកលើគណបក្ស នៅទូទាំងប្រទេស។ ផលប៉ះ**ពាល់សារពើពន្ធ៖** ការចំណាយតែមួយលើកសម្រាប់មូលដ្ឋានឆ្នោត អាចមានចំនួនរហូតដល់ពីរបីលានដុល្លារ ទូទាំងរដ្ឋ ដើម្បីកែប្រែឯកសារបោះឆ្នោត ឲ្យឆ្លុះបញ្ចាំងផែនទីតំបន់តំណាងសភាថ្មី។

## ការបោះឆ្នោតរបស់អ្នកមានសារៈសំខាន់អ្វីខ្លះ

**បាទ**/ចាស បោះឆ្នោតគាំទ្រលើវិធានការនេះមានន័យថា៖ រដ្ឋនឹងប្រើផែនទីតំបន់តំណាងសភាដែលបានគូសថ្មចាប់ពីឆ្នាំ 2026 តទៅ។ ផែនទីថ្មីរបស់រដ្ឋ California នឹងត្រូវបានប្រើរហូតដល់គណៈកម្មការបែងចែកតំបន់សារឡើងវិញរបស់ពេលរដ្ឋនៅរដ្ឋ California គូសផែនទីថ្មីបន្ទាប់ពីជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2030។

**ទេ** បោះឆ្នោតប្រឆាំងនឹងវិធានការមានន័យថា៖ ផែនទីតំបន់តំណាងសភាបច្ចុប្បន្នដែលគូសដោយគណៈកម្មការបែងចែកតំបន់សារឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California (គណៈកម្មការ) នឹងត្រូវបានបន្តប្រើនៅក្នុងរដ្ឋ California រហូតដល់គណៈកម្មការគូសផែនទីថ្មីបន្ទាប់ពីជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2030។

## ទឡ្ហីករណ៍

**គាំទ្រ** សំណើទី 50—ច្បាប់ស្តីពីការឆ្លើយតបនឹងការលួចបន្លំសន្លឹកឆ្នោត—យល់ព្រមលើផែនទីតំបន់តំណាងសភាបណ្តោះអាសន្នបន្ទាន់ ដើម្បីប្រឆាំងនឹងផែនការរបស់លោក Donald Trump ក្នុងការលួចបន្លំការបោះឆ្នោតសភានៅឆ្នាំបន្ទាប់ និងអះអាងជាថ្មីអំពីការប្តេជ្ញារបស់រដ្ឋ California ចំពោះការបែងចែកតំបន់សារឡើងវិញដោយឯករាជ្យមិនចូលខាងគណបក្សណាមួយ នៅក្រោយជំរឿនបន្ទាប់។ បោះឆ្នោតគាំទ្រលើសំណើទី 50 ដើម្បីប្រជាធិបតេយ្យនៅក្នុងរដ្ឋទាំង 50។ ស្វែងយល់បន្ថែមតាមរយៈ *StopElectionRigging.com*។

**ប្រឆាំង** សំណើទី 50 ត្រូវបានសរសេរឡើងដោយអ្នកនយោបាយ ដើម្បីអ្នកនយោបាយ—ដកចេញនូវការការពារដែលរក្សាការបោះឆ្នោតឱ្យមានភាពយុត្តិធម៌ ដកចេញនូវលក្ខខណ្ឌតម្រូវក្នុងការរក្សាសហគមន៍មូលដ្ឋានជាមួយគ្នា និងលុបបំបាត់ការការពារអ្នកបោះឆ្នោតដែលហាមឃាត់ផែនទីដែលរៀបចំ ដើម្បីផ្តល់ប្រយោជន៍ដល់គណបក្សនយោបាយ។ បោះឆ្នោតប្រឆាំងដើម្បីការពារការបោះឆ្នោតប្រកបដោយយុត្តិធម៌ និងរក្សាប្រជាជនដែលទទួលបន្ទុកក្នុងការបែងចែកតំបន់ឡើងវិញ មិនមែនអ្នកនយោបាយនោះទេ។

## សម្រាប់ព័ត៌មានបន្ថែម

**សម្រាប់**

អភិបាល Gavin Newsom
គាំទ្រលើសំណើទី 50 ច្បាប់ស្តីពីការឆ្លើយតបនឹងការលួចបន្លំសន្លឹកឆ្នោត
គណៈកម្មាធិការវិធានការសន្លឹកឆ្នោតរបស់អភិបាល Newsom
555 Capitol Mall, Suite 400
Sacramento, CA 95814
info@stopelectionrigging.com
StopElectionRigging.com

**ប្រឆាំង**

ប្រឆាំងនឹងសំណើទី 50—ការពារអ្នកបោះឆ្នោតជាអាទិភាព គាំទ្រដោយឱ្យអ្នកនយោបាយទទួលខុសត្រូវ
2350 Kerner Blvd., Suite 250
San Rafael, CA 94901
(916) 446-6572
info@votersfirstact.org
VotersFirstAct.org

# ព័ត៌មានថ្ងៃបោះឆ្នោត

ទីតាំងបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ នៅថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ ប្រសិនជាអ្នកកំពុង តម្រង់ជួរមុនម៉ោង 8:00 យប់ អ្នកនៅតែអាចបោះឆ្នោតបាន។

# ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ឬមជ្ឈមណ្ឌលបោះឆ្នោត

កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវបានបង្កើតឡើងដោយមន្ត្រីរៀបចំការបោះឆ្នោតខោនធី។ សូមរកមើលអាសយដ្ឋានកន្លែងបោះឆ្នោតរបស់អ្នក ឬទីតាំងមណ្ឌលបោះឆ្នោតនៅក្នុងមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមខោនធីដែលអ្នកបានទទួលតាមសំបុត្រពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត។

អ្នកក៏អាចចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការនៅតាមរយៈ *vote.ca.gov* ឬហៅទូរសព្ទទៅលេខទូរសព្ទអ្នកបោះឆ្នោតដោយមិនគិតថ្លៃរបស់យើងតាមលេខ (888) 345-4917។




លទ្ធផលបោះឆ្នោតសម្រាប់ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូលនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025 គឺអាចរកបាន បន្ទាប់ពីការបោះឆ្នោតបិទនៅម៉ោង 8:00 យប់ នៅលើគេហទំព័រលទ្ធផលការបោះឆ្នោតរបស់រដ្ឋលេខាធិការនៃរដ្ឋ California តាមរយៈ *electionresults.sos.ca.gov*។

លទ្ធផលនឹងចាប់ផ្តើមប្រកាសនៅម៉ោង 8:00 យប់ ហើយនឹងត្រូវបានធ្វើបច្ចុប្បន្នពេញមួយយប់នៃការបោះឆ្នោត។ នៅថ្ងៃបន្ទាប់ លទ្ធផលនឹងធ្វើបច្ចុប្បន្នភាពនៅម៉ោង 5:00 ល្ងាច រៀងរាល់ថ្ងៃពេញមួយ canvass ខណៈដែលខោនធីរាប់សន្លឹកឆ្នោតសេសសល់។

លទ្ធផលដែលបានបញ្ជាក់ជាផ្លូវការនៃការបោះឆ្នោតនឹងត្រូវប្រកាសត្រឹមថ្ងៃទី 12 ខែធ្នូ ឆ្នាំ 2025 តាមរយៈ *sos.ca.gov/elections*។

# ថ្ងៃកាន់តែច្រើន វិធីច្រើនទៀតដើម្បីបោះឆ្នោត

## ជាមួយនឹងច្បាប់នៃជម្រើសរបស់អ្នកបោះឆ្នោតច្បាប់រដ្ឋ California




### បោះឆ្នោតដោយផ្ទាល់បានរហូតដល់ 10 ថ្ងៃមុនថ្ងៃបោះឆ្នោត

- Alameda
- Amador
- Butte
- Calaveras
- El Dorado
- Fresno
- Humboldt
- Kings
- Los Angeles
- Madera
- Marin
- Mariposa
- Merced
- Napa
- Nevada
- Orange
- Placer
- Riverside
- Sacramento
- San Benito
- San Diego
- San Mateo
- Santa Clara
- Santa Cruz
- Sonoma
- Stanislaus
- Tuolumne
- Ventura
- Yolo

**នៅរដ្ឋ California អ្នកចុះឈ្មោះបោះឆ្នោតសកម្មគ្រប់រូបនឹងទទួលបានសន្លឹកឆ្នោតដោយស្វ័យប្រវត្តិនៅក្នុងប្រអប់សំបុត្រ មុនការបោះឆ្នោតនីមួយៗ។** ពិនិត្យស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ដើម្បីប្រាកដថាអ្នកទទួលបានសន្លឹកឆ្នោតរបស់អ្នក។

### ប្រើប្រអប់ទម្លាក់សន្លឹកឆ្នោត ៖

បញ្ជូនត្រលប់សន្លឹកឆ្នោតរបស់អ្នកទៅទីតាំងទម្លាក់ដែលមានសុវត្ថិភាពនៅក្នុងខោនធីណាមួយបាន**រហូតដល់ 28 ថ្ងៃមុនថ្ងៃបោះឆ្នោត**

### មណ្ឌលបោះឆ្នោត ៖

- បោះឆ្នោតដោយខ្លួនឯង គ្រប់ទីកន្លែងក្នុងខោនធី **រហូតដល់ 10 ថ្ងៃ មុនការបោះឆ្នោត**
- ចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតនៅថ្ងៃដដែល
- ទម្លាក់សន្លឹកឆ្នោតរបស់អ្នក

### បោះឆ្នោតតាមប្រអប់សំបុត្រ ៖

សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ **ដរាបណាអ្នកទទួលបានសំបុត្រនោះ**

**សូមទស្សនា RegisterToVote.ca.gov ឬហៅទូរសព្ទមកលេខ (888) 345-4917 ដើម្បីឈ្វេងយល់បន្ថែម។**

CALIFORNIA VOTER'S CHOICE ACT

VCA.SOS.CA.GOV

ចង់ចៀសវាងពីការតម្រង់ជួរ និងបោះឆ្នោតឱ្យបានមុនឬ? **ស្កេនកូដ QR ដើម្បីស្វែងយល់បន្ថែម!**

# កុំពន្យារពេល សូមបោះឆ្នោតនៅថ្ងៃនេះ!

អ្នកបោះឆ្នោតរដ្ឋ California ទាំងអស់នឹងទទួលសន្លឹកបោះឆ្នោតតាមសំបុត្រជាមួយនឹងស្រោមសំបុត្រត្រឡប់មកវិញដោយបង់ប្រាក់ជាមុនសម្រាប់ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូលនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ មន្ត្រីរៀបចំការបោះឆ្នោតខោនធីនឹងចាប់ផ្តើមផ្ញើសន្លឹកបោះឆ្នោតតាមសំបុត្រមិនឱ្យលើសពីថ្ងៃទី 6 ខែតុលា ឆ្នាំ 2025 ឡើយ។

រយៈពេលបោះឆ្នោតតាមសំបុត្រចាប់ផ្តើមភ្លាមៗ នៅពេលដែលសន្លឹកឆ្នោតមាននៅក្នុងសំបុត្រ។ ធ្វើឱ្យសំឡេងរបស់អ្នកបានឮជាមុន! សូមផ្ញើសន្លឹកបោះឆ្នោតតាមសំបុត្ររបស់អ្នកត្រឡប់មកវិញក្នុងអំឡុងពេលបោះឆ្នោតថ្ងៃទី 6 ខែតុលា រហូតដល់ការបិទការបោះឆ្នោតនៅថ្ងៃទី 4 ខែវិច្ឆិកា។

## ការបោះឆ្នោតតាមសំបុត្រគឺងាយស្រួល។

លទ្ធិប្រជាធិបតេយ្យកំពុងពឹងលើអ្នក! សូមអនុវត្តតាមជំហានងាយៗទាំងប្រាំនេះ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់អ្នក៖

**បំពេញវា។**

គូសយកជម្រើសរបស់អ្នកនៅលើសន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក។

**បិទភ្ជិតវា។**

ធានាសន្លឹកឆ្នោតរបស់អ្នកនៅក្នុងស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតតាមសំបុត្រ ដែលអ្នកបានទទួលពីការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

**ចុះហត្ថលេខាលើវា។**

ចុះហត្ថលេខានៅខាងក្រៅស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក។

ត្រូវប្រាកដថាហត្ថលេខារបស់អ្នកត្រូវគ្នានឹងបណ្ណបើកបរ/លេខសម្គាល់រដ្ឋ CA របស់អ្នក ឬមួយណាដែលអ្នកបានផ្តល់នៅពេលចុះឈ្មោះបោះឆ្នោត។ ការិយាល័យបោះឆ្នោតខោនធីរបស់អ្នកនឹងប្រៀបធៀបពួកបណ្ណសម្គាល់នោះ មុនពេលពួកគេរាប់សន្លឹកឆ្នោតរបស់អ្នក។

**ផ្ញើវាត្រឡប់មកវិញ។**

<u>តាមរយៈប្រអប់ទម្លាក់សំបុត្រ</u>—ទម្លាក់សន្លឹកបោះឆ្នោតតាមសំបុត្រដែលអ្នកបានបំពេញនៅប្រអប់ទម្លាក់សំបុត្រដែលមានសុវត្ថិភាពនៅក្នុងខោនធីរបស់អ្នកគ្រប់ពេលនៅចន្លោះថ្ងៃទី 7 ខែតុលា រហូតដល់ថ្ងៃបិទការបោះឆ្នោតនៅថ្ងៃទី 4 ខែវិច្ឆិកា។

<u>ដោយផ្ទាល់</u>—ទម្លាក់សន្លឹកបោះឆ្នោតតាមសំបុត្រដែលអ្នកបានបំពេញនៅប្រអប់ទម្លាក់សំបុត្រសុវត្ថិភាព កន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬការិយាល័យបោះឆ្នោតខោនធី ត្រឹមម៉ោង 8:00 យប់ នៅថ្ងៃទី 4 ខែវិច្ឆិកា។ ទីតាំងបោះឆ្នោតនឹងមាននៅគ្រប់ខោនធីទាំងអស់ មុនថ្ងៃបោះឆ្នោត។ ទីតាំងបោះឆ្នោតផ្តល់ជូនការចុះឈ្មោះអ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន និងជំនួយភាសា។

<u>តាមសំបុត្រ</u>—សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រដរាបណាអ្នកទទួលបានសំបុត្រនោះ។ ត្រូវប្រាកដថាស្រោមសំបុត្រប្រគល់សន្លឹកបោះឆ្នោតតាមសំបុត្ររបស់អ្នកត្រូវបានបោះត្រាមិនឱ្យលើសពីថ្ងៃទី 4 ខែវិច្ឆិកា។

**តាមដានវា។**

ចុះឈ្មោះតាម *wheresmyballot.sos.ca.gov* ដើម្បីទទួលបានព័ត៌មានថ្មីៗអំពីស្ថានភាពសន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក តាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង។




អ្នកបោះឆ្នោតទាំងអស់អាចទទួលបានព័ត៌មានសំខាន់ៗថ្មីៗអំពីសន្លឹកឆ្នោតរបស់ខ្លួនតាមរយៈឧបករណ៍តាមដានផ្លូវការ "សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?" របស់រដ្ឋ California។ **ការចុះឈ្មោះចំណាយពេលតិចជាងបីនាទី!**

***អ្វីដែលអ្នកនឹងអាចតាមដាន៖***




អ្នកអាចជ្រើសរើសដើម្បីទទួលការជូនដំណឹងអំពីស្ថានភាពសន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក តាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង រួមទាំងការជូនដំណឹង ប្រសិនបើមានបញ្ហាជាមួយសន្លឹកឆ្នោតរបស់អ្នក និងការណែនាំសម្រាប់របៀបកែតម្រូវវាដើម្បីប្រាកដថាអ្នក ការបោះឆ្នោតត្រូវបានរាប់។

កុំខកខានឱកាសដើម្បីតាមដានសន្លឹកឆ្នោតរបស់អ្នកគ្រប់ជំហាន!

អ្នកក៏អាចចម្លង URL នេះទៅក្នុងកម្មវិធីរុករករបស់អ្នកដាក់ថា៖ ***wheresmyballot.sos.ca.gov***

50

សំណើ

# 50 អនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាបណ្តោះអាសន្នលើផែនទីតំបន់តំណាងសភា ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់ សារឡើងវិញរបស់រដ្ឋ TEXAS តាមផ្អែកលើគណបក្ស។ ការកែប្រែរដ្ឋធម្មនុញ្ញដោយសភានីតិបញ្ញត្តិ។

**ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប** រៀបចំដោយអគ្គព្រះរាជអាជ្ញា

**អត្ថបទស្តីពីវិធានការនេះអាចរកបាននៅទំព័រទី 18 និងនៅវិបសាយថ៍រដ្ឋលេខាធិការតាមរយៈ *voterguide.sos.ca.gov*។**

- ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់ សារឡើងវិញ តំណាងសភាពាក់កណ្តាលទសវត្សរ៍របស់រដ្ឋ Texas ដែលផ្អែកលើគណបក្ស សំណើនេះតម្រូវឱ្យប្រើផែនទីតំបន់តំណាងសភាថ្មី ដែលសភានីតិបញ្ញត្តិបានអនុម័តនៅខែសីហា ឆ្នាំ 2025 ក្នុងការបោះ ឆ្នោតសភាតំណាងអាមេរិករបស់រដ្ឋ California រហូតដល់ឆ្នាំ 2030។
- បន្តរក្សាគណៈកម្មការបែងចែកតំបន់ សារឡើងវិញ ឯករាជ្យរបស់ពលរដ្ឋ California និងបញ្ជាឲ្យគណៈកម្មការនេះបន្តកំណត់ផែនទីតំបន់តំណាងសភាឡើងវិញក្នុងឆ្នាំ 2031 បន្ទាប់ពីបញ្ជីការស្រង់ចំនួនប្រជាជនឆ្នាំ 2030 ហើយរៀងរាល់ ដប់ ឆ្នាំបន្ទាប់។
- បង្កើតគោលនយោបាយរដ្ឋ ដើម្បីគាំទ្រការប្រើប្រាស់គណៈកម្មការបែងចែកតំបន់ សារឡើងវិញ តំណាងសភាដែលមានតម្លាភាព ឯករាជ្យ និងមិនផ្អែកលើគណបក្ស នៅទូទាំងប្រទេស។

**សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិ អំពីផលប៉ះពាល់សារ ពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖**

- ការចំណាយតែមួយលើកសម្រាប់មូលដ្ឋានឆ្នោត អាចមានចំនួនរហូតដល់ពីរបីលាន ដុល្លារទូទាំងរដ្ឋ។ ការចំណាយរបស់មូលដ្ឋានឆ្នោតគឺសម្រាប់កែប្រែឯកសារបោះឆ្នោត ដើម្បីឲ្យឆ្លុះបញ្ចាំងផែនទីតំបន់តំណាងសភាថ្មី។

---

ការបោះឆ្នោតជ្រើសរើសចុងក្រោយដោយអង្គនីតិបញ្ញត្តិលើ ACA 8 (សំណើទី 50)
(ជំណោះស្រាយ ជំពូកទី 156 លក្ខន្តិកៈឆ្នាំ 2025)

| | | |
|---|---|---|
| ព្រឹទ្ធសភា៖ | បោះឆ្នោតគាំទ្រ 30 | បដិសេធ 8 |
| សភា៖ | បោះឆ្នោតគាំទ្រ 57 | បដិសេធ 20 |

---

**ការវិភាគដោយអ្នកវិភាគច្បាប់**

## ផ្ទៃខាងក្រោយ

### សភាសហរដ្ឋអាមេរិក

***សភាសហរដ្ឋអាមេរិក។*** សភាសហរដ្ឋអាមេរិកគឺជាផ្នែកមួយនៃរដ្ឋាភិបាលសហព័ន្ធដែលបង្កើតច្បាប់។ សភាពមានពីរ៖ ព្រឹទ្ធសភាសហរដ្ឋអាមេរិក និងរដ្ឋសភាសហរដ្ឋអាមេរិក (រដ្ឋសភា)។ រដ្ឋនីមួយៗនៃរដ្ឋទាំង 50 តំណាងដោយសមាជិកព្រឹទ្ធសភា 2 រូប ដែលមានសមាជិកព្រឹទ្ធសភាសរុប 100 រូប។ រដ្ឋសភាមានសមាជិក 435 រូប។ ចំនួនអ្នកតំណាងនៅក្នុងរដ្ឋសភាសម្រាប់រដ្ឋនីមួយៗគឺអាស្រ័យលើចំនួនមនុស្សដែលរស់នៅក្នុងរដ្ឋនោះ។ សមាជិកម្នាក់ៗនៅក្នុងរដ្ឋសភាតំណាងឱ្យតំបន់នៃរដ្ឋដែលគេហៅថាតំបន់តំណាងសភា។ បច្ចុប្បន្ន រដ្ឋ California មានតំបន់តំណាងសភា 52។ អ្នកបោះឆ្នោតដែលរស់នៅក្នុងតំបន់តំណាងសភានីមួយៗបោះឆ្នោតជ្រើសរើសសមាជិកសភាមួយរូបរៀងរាល់ពីរឆ្នាំម្តង ដើម្បីធ្វើជាតំណាង។ ការបោះឆ្នោតបន្ទាប់សម្រាប់អ្នកតំណាងទាំង 435 រូបនឹងធ្វើឡើងនៅឆ្នាំ 2026។

***ជំរឿនសហរដ្ឋអាមេរិកធ្វើជំរឿនប្រជាជននៅក្នុងរដ្ឋរៀងរាល់ដប់ឆ្នាំម្តង។*** ចំនួនមនុស្សរស់នៅក្នុងតំបន់កើនឡើង និងថយចុះទៅតាមពេលវេលា។ រៀងរាល់ដប់ឆ្នាំម្តង ជំរឿនសហរដ្ឋអាមេរិកធ្វើជំរឿនចំនួនប្រជាជនដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ ជំរឿនចុងក្រោយធ្វើឡើងនៅក្នុងឆ្នាំ 2020 ហើយជំរឿនបន្ទាប់ធ្វើឡើងនៅឆ្នាំ 2030។ ការធ្វើជំរឿននេះត្រូវបានប្រើដើម្បីកំណត់ចំនួនមនុស្សដែលរស់នៅក្នុងរដ្ឋនីមួយៗ និងចំនួនអ្នកតំណាងនៅក្នុងរដ្ឋសភាដែលរដ្ឋនីមួយៗមានសម្រាប់ដប់ឆ្នាំបន្ទាប់។

### ការបែងចែកតំបន់តំណាងសភាសារឡើងវិញ

***រដ្ឋនីមួយៗគូសផែនទីតំបន់តំណាងសភាបន្ទាប់ពីជំរឿនសហរដ្ឋអាមេរិក។*** រៀងរាល់ដប់ឆ្នាំម្តង បន្ទាប់ពីបញ្ចប់ជំរឿនសហរដ្ឋអាមេរិក រដ្ឋនានាធ្វើការគូសផែនទីតំបន់តំណាងសភាថ្មី ដើម្បីឆ្លុះបញ្ចាំងពីចំនួនអ្នកតំណាងរដ្ឋសភារបស់ខ្លួន និងកន្លែងដែលប្រជាពលរដ្ឋរស់នៅ។ ដំណើរការនេះហៅថា "ការបែងចែកសារឡើងវិញ"។ រដ្ឋនីមួយៗសម្រេចចិត្តលើដំណើរការណាដែលត្រូវប្រើសម្រាប់គូសផែនទីតំបន់ថ្មី។ នៅពេលគូសផែនទីថ្មី រដ្ឋនីមួយៗត្រូវតែអនុលោមតាមច្បាប់សហព័ន្ធ។ ឧទាហរណ៍ តំបន់តំណាងសភានីមួយៗនៅក្នុងរដ្ឋត្រូវតែតំណាងអំពីចំនួនប្រជាជនដូចគ្នា។

***ជាទូទៅ រដ្ឋមិនធ្វើការបែងចែកឡើងវិញមុនរៀងរាល់ដប់ឆ្នាំម្តងទេ។*** ជាទូទៅរដ្ឋគ្រាន់តែគូសផែនទីតំបន់តំណាងសភារៀងរាល់ដប់ឆ្នាំម្តងប៉ុណ្ណោះ លើកលែងតែតុលាការបង្គាប់ឱ្យធ្វើការផ្លាស់ប្តូរដើម្បីអនុលោមតាមច្បាប់។ ទោះយ៉ាងណាក៏ដោយ នៅខែសីហា ឆ្នាំ 2025 អង្គនីតិបញ្ញត្តិរដ្ឋ Texas បានអនុម័តច្បាប់កែសម្រួលផែនទីថ្មីសម្រាប់ការបោះឆ្នោតឆ្នាំ 2026 ដោយគ្មានដីកាបង្គាប់របស់តុលាការ។ រដ្ឋមួយចំនួនផ្សេងទៀតក៏កំពុងពិចារណាផ្លាស់ប្តូរផែនទីរបស់ខ្លួននៅមុនការបោះឆ្នោតឆ្នាំ 2026 ផងដែរ។

**ការវិភាគដោយ អ្នកវិភាគច្បាប់** បន្ត

***ការបែងចែកតំបន់តំណាងសភាសារឡើងវិញនៅរដ្ឋ California។*** អង្គនីតិបញ្ញត្តិរដ្ឋបានគូសផែនទីតំបន់តំណាងសភានៅក្នុងរដ្ឋភាគច្រើន ប៉ុន្តែមានរដ្ឋមួយចំនួនប្រើប្រាស់គណៈកម្មការឱ្យធ្វើកិច្ចការនេះ។ នៅមុនឆ្នាំ 2010 អង្គនីតិបញ្ញត្តិរដ្ឋ California បានគូសផែនទីតំបន់តំណាងសភារបស់រដ្ឋ។ ក្នុងឆ្នាំ 2010 អ្នកបោះឆ្នោតនៅរដ្ឋ California បានប្រគល់កិច្ចការនេះទៅឱ្យគណៈកម្មការឯករាជ្យដែលគេស្គាល់ថា គណៈកម្មការបែងចែកសារឡើងវិញរបស់ប្រជាពលរដ្ឋនៅរដ្ឋ California (គណៈកម្មការ)។ គណៈកម្មការនេះមានសមាជិក 14 រូប៖ សមាជិកពីគណបក្សប្រជាធិបតេយ្យ 5 រូប សមាជិកពីគណបក្សសាធារណរដ្ឋ 5 រូប និងសមាជិក 4 រូបមកពីគណបក្សនយោបាយផ្សេង។ នៅពេលគណៈកម្មការគូសផែនទីតំបន់តំណាងសភាថ្មី គណៈកម្មការត្រូវតែអនុវត្តតាមច្បាប់រដ្ឋ និងសហព័ន្ធ។ ឧទាហរណ៍ ច្បាប់រដ្ឋតម្រូវឱ្យគណៈកម្មការចៀសវាងការបំបែកតំបន់ ឬសហគមន៍ក្នុងតំបន់ដែលពាក់ព័ន្ធតាមទំហំដែលអាចធ្វើទៅបាន។ ច្បាប់រដ្ឋក៏ហាមឃាត់មិនឱ្យគណៈកម្មការពិចារណាលើគណបក្សនយោបាយ អ្នកមានតួនាទីក្នុងការិយាល័យបច្ចុប្បន្ន ឬបុគ្គលដែលកាន់ការក្នុងការិយាល័យនៅពេលធ្វើការគូសផែនទីឡើយ។

***តំបន់តំណាងសភាបច្ចុប្បន្ននៅរដ្ឋ California។*** គណៈកម្មការបានគូសផែនទីបច្ចុប្បន្នសម្រាប់តំបន់តំណាងសភាទាំង 52 របស់រដ្ឋ California។ ផែនទីទាំងនេះធ្វើឡើងដោយផ្អែកលើជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2020 និងត្រូវបានប្រើចាប់តាំងពីការបោះឆ្នោតសភាឆ្នាំ 2022។

# សំណើ

## ផែនទីតំបន់តំណាងសភារដ្ឋ CALIFORNIA

***ប្រើផែនទីតំបន់តំណាងសភាដែលបានគូសដោយស្របច្បាប់រហូតដល់ក្រោយជំរឿនបន្ទាប់។*** សំណើទី 50 ជំនួសផែនទីតំបន់តំណាងសភាបច្ចុប្បន្នរបស់រដ្ឋ California ដោយផែនទីថ្មីដែលបានគូសដោយស្របច្បាប់។ (ចំនួនតំបន់តំណាងសរុបនឹងមិនប្រែប្រួលទេ។) ផែនទីរបស់សំណើទី 50 ត្រូវតែអនុលោមតាមច្បាប់សហព័ន្ធ ប៉ុន្តែវាមិនត្រូវបានតម្រូវឱ្យអនុលោមតាមលក្ខខណ្ឌតម្រូវថ្នាក់រដ្ឋដែលដាក់លើគណៈកម្មការឡើយ។ រដ្ឋនឹងប្រើផែនទីរបស់សំណើទី 50 សម្រាប់ការបោះឆ្នោតសភាចាប់ពីឆ្នាំ 2026 តទៅ។ រដ្ឋនឹងប្រើផែនទីទាំងនេះរហូតដល់គណៈកម្មការគូសផែនទីតំបន់ថ្មី បន្ទាប់ពីជំរឿនសហរដ្ឋអាមេរិកឆ្នាំ 2030។

## ការបែងចែកតំបន់តំណាងសភាសារឡើងវិញថ្នាក់ជាតិ

***អំពាវនាវឱ្យធ្វើការកែប្រែច្បាប់សហព័ន្ធ។*** សំណើទី 50 ស្នើសុំឱ្យសភាសហរដ្ឋអាមេរិកកែប្រែច្បាប់សហព័ន្ធ និងស្នើសុំវិសោធនកម្មរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដោយតម្រូវឱ្យធ្វើការបែងចែកតំបន់តំណាងសភាសារឡើងវិញដោយ "គណៈកម្មការបែងចែកតំបន់តំណាងសភាឯករាជ្យ និងយុត្តិធម៌ដោយមិនចូលខាងគណបក្សណាមួយនៅទូទាំងប្រទេស"។ សំណើទី 50 បង្ហាញពីការគាំទ្ររបស់អ្នកបោះឆ្នោតចំពោះគំនិតនេះ ប៉ុន្តែមិនកែប្រែច្បាប់សហព័ន្ធ ឬតម្រូវឱ្យមានវិធានការជាក់លាក់ពីសភា ឬអង្គនីតិបញ្ញត្តិរដ្ឋ California ឡើយ។

# ផលប៉ះពាល់សារពើពន្ធ

***ការចំណាយតែមួយលើកតិចតួចសម្រាប់មន្ត្រីរៀបចំការបោះឆ្នោតខោនធី និងរដ្ឋ។*** ខោនធីដំណើរការការបោះឆ្នោត ហើយរដ្ឋត្រួតពិនិត្យលើខោនធីទាំងនោះ។ ដោយសារតំបន់តំណាងសភាភាគច្រើននៅរដ្ឋ California នឹងប្រែប្រួលយ៉ាងហោចណាស់ខ្លះៗនៅក្រោមផែនទីថ្មី មន្ត្រីរៀបចំការបោះឆ្នោតខោនធី និងរដ្ឋនឹងត្រូវធ្វើបច្ចុប្បន្នភាពសម្ភារៈបោះឆ្នោត។ នេះនឹងបង្កើតជាការចំណាយតែមួយលើកដល់ខោនធី**ក្នុងទំហំរហូតដល់ពីរបីលានដុល្លារ**នៅទូទាំងរដ្ឋ និងការចំណាយតែមួយលើកដល់រដ្ឋ**ប្រហែល $200,000**។ ចំនួនទឹកប្រាក់ថ្នាក់រដ្ឋនេះគឺមានចំនួនតិចជាងមួយភាគដប់នៃ 1 ភាគរយ (0.1 ភាគរយ) នៃថវិកាមូលនិធិទូទៅទំហំប្រហែល $220 ពាន់លានរបស់រដ្ឋ។ (មូលនិធិទូទៅគឺជាគណនីដែលរដ្ឋប្រើដើម្បីបង់ថ្លៃសេវាសាធារណៈភាគច្រើន រួមទាំងការអប់រំ ការថែទាំសុខភាព និងពន្ធនាគារ។)

# ផែនទីតំបន់តំណាងសភាបច្ចុប្បន្ន និងផែនទីដែលស្នើ

ផ្នែកនេះបង្ហាញពីផែនទីតំបន់តំណាងសភាបច្ចុប្បន្ន និងផែនទីដែលស្នើ (1) នៅទូទាំងរដ្ឋ ដូចបង្ហាញនៅក្នុងរូបភាពទី 1 និងទី 2, (2) នៅតំបន់ភាគខាងជើងនៃរដ្ឋ ដូចបង្ហាញក្នុងរូបភាពទី 3 និងទី 4 និង (3) នៅតំបន់ភាគខាងត្បូងនៃរដ្ឋ ដូចបង្ហាញនៅក្នុងរូបភាពទី 5 និងទី 6។ អ្នកអាចរកឃើញការពណ៌នាអំពីប្លុកជំរឿនដែលតំណាងដោយតំបន់តំណាងនីមួយៗនៅក្នុងផែនទីដែលស្នើនៅក្នុងគេហទំព័រនេះ៖ *https://leginfo.legislature.ca.gov/faces/billNavClient.xhtml?bill_id=202520260AB604*

**ចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2025-ballot-measure-contribution-totals* សម្រាប់បញ្ជីគណៈកម្មាធិការដែលបង្កើតឡើងដើម្បីគាំទ្រ ឬប្រឆាំងនឹងវិធានការនេះ។**

**ចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលអ្នកចូលរួមវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**

សំណើ **50** អនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាបណ្តោះអាសន្នលើផែនទីតំបន់តំណាងសភា ដើម្បីឆ្លើយតបចំពោះការបែងចែកតំបន់ សារឡើងវិញរបស់រដ្ឋ TEXAS តាមផ្អែកលើគណបក្ស។ ការកែប្រែរដ្ឋធម្មនុញ្ញដោយសភានីតិបញ្ញត្តិ។

## ការវិភាគដោយអ្នកវិភាគច្បាប់

បន្ត

រូបភាពទី 1

### តំបន់តំណាងសភាបច្ចុប្បន្ន




ចំណាំ៖ សូមមើលផែនទីតំបន់តំណាងសភាភាគខាងជើង និងខាងត្បូងសម្រាប់ចំនួនតំបន់តំណាងសម្រាប់តំបន់ Bay Area និង Los Angeles។ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះលើគេហទំព័រគណៈកម្មការបែងចែកតំបន់តំណាងសភាឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California។

## ការវិភាគដោយអ្នកវិភាគច្បាប់



រូបភាពទី 2

### តំបន់តំណាងសភាដែលស្នើ




ចំណាំ៖ សូមមើលផែនទីតំបន់តំណាងសភាភាគខាងជើង និងខាងត្បូងសម្រាប់ចំនួនតំបន់តំណាងសម្រាប់តំបន់ Bay Area និង Los Angeles។ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះនៅលើគេហទំព័ររបស់គណៈកម្មាធិការបោះឆ្នោតនៃអង្គនីតិបញ្ញត្តិរដ្ឋ California (គណៈកម្មាធិការបោះឆ្នោតសភា និងការបោះឆ្នោតព្រឹទ្ធសភា និងគណៈកម្មាធិការវិសោធនកម្មរដ្ឋធម្មនុញ្ញ)។

សម្រាប់អត្ថបទពេញលេញនៃសំណើទី 50 សូមមើលទំព័រទី 18។

## ការវិភាគដោយអ្នកវិភាគច្បាប់

បន្ត

រូបភាពទី 3

### តំបន់តំណាងសភាភាគខាងជើងបច្ចុប្បន្ន




ចំណាំ៖ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះលើគេហទំព័រគណៈកម្មការបែងចែកតំបន់តំណាងសភាឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California។

## ការវិភាគដោយអ្នកវិភាគច្បាប់



រូបភាពទី 4

### តំបន់តំណាងសភាភាគខាងជើងដែលស្នើ




ចំណាំ៖ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះនៅលើគេហទំព័ររបស់គណៈកម្មាធិការបោះឆ្នោតនៃអង្គនីតិបញ្ញត្តិរដ្ឋ California (គណៈកម្មាធិការបោះឆ្នោតសភា និងការបោះឆ្នោតព្រឹទ្ធសភា និង គណៈកម្មាធិការវិសោធនកម្មរដ្ឋធម្មនុញ្ញ)។

សម្រាប់អត្ថបទពេញលេញនៃសំណើទី 50 សូមមើលទំព័រទី 18។

## ការវិភាគដោយអ្នកវិភាគច្បាប់

បន្ត

រូបភាពទី 5

### តំបន់តំណាងសភាភាគខាងត្បូងបច្ចុប្បន្ន




ចំណាំ៖ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះលើគេហទំព័រគណៈកម្មការបែងចែកតំបន់តំណាងសភាឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California។

## ការវិភាគដោយអ្នកវិភាគច្បាប់

បន្ត

រូបភាពទី 6

### តំបន់តំណាងសភាភាគខាងត្បូងដែលស្នើ




ចំណាំ៖ ផែនទីឆ្លុះបញ្ចាំងអំពីទិន្នន័យដែលបង្ហោះនៅលើគេហទំព័ររបស់គណៈកម្មាធិការបោះឆ្នោតនៃអង្គនីតិបញ្ញត្តិរដ្ឋ California (គណៈកម្មាធិការបោះឆ្នោតសភា និងការបោះឆ្នោតព្រឹទ្ធសភា និង គណៈកម្មាធិការវិសោធនកម្មរដ្ឋធម្មនុញ្ញ)។

សម្រាប់អត្ថបទពេញលេញនៃសំណើទី 50 សូមមើលទំព័រទី 18។

## ★ ទឡ្ហីករណ៍គាំទ្រសំណើ 50 ★

*បញ្ឈប់មិនឱ្យលោក Trump លួចបន្លំនៅការបោះឆ្នោតឆ្នាំ 2026*

Donald Trump និងគណបក្សសាធារណរដ្ឋនៅរដ្ឋ Texas កំពុងក្រសោបយកអំណាច ដើម្បីលួចកៅអីសភា និងលួចបន្លំការបោះឆ្នោតឆ្នាំ 2026 នៅមុនការបោះឆ្នោតចាប់ផ្តើមទៅទៀត។

រដ្ឋដែលកាន់កាប់ដោយគណបក្សសាធារណរដ្ឋផ្សេងទៀតកំពុងធ្វើបែបនេះដូចគ្នា។ ពួកគេចង់លួចកៅអីដើម្បីកាន់កាប់សភា ទោះបីជាអ្នកបោះឆ្នោតបដិសេធដាច់ខាតចំពោះរបៀបវារៈរបស់ពួកគេក៏ដោយ។

នេះមិនមែនជារឿងនយោបាយធម្មតាទេ។ វាជាសញ្ញាអាសន្នសម្រាប់ប្រជាធិបតេយ្យរបស់យើង។

*ធានានូវការតំណាងដោយយុត្តិធម៌នៅក្នុងសភា*

យើងបានឃើញហើយថាលោក Trump បានដាក់ពន្ធគយដោយគ្មានការពិចារណ៍ និងបង្កការឈឺចាប់ដល់គ្រួសារនៅក្នុងរដ្ឋ California បដិសេធការផ្តល់ជំនួយគ្រោះមហន្តរាយដល់ជនរងគ្រោះដោយសារអគ្គិភ័យ និងបង្គាប់ឱ្យមានការចាប់ខ្លួនទ្រង់ទ្រាយធំដោយគ្មានដីកា។ ការបោះឆ្នោតជ្រើសរើសសភាឆ្នាំ 2026 គឺជាឱកាសតែមួយគត់ដែលយើងមាន ដើម្បីធ្វើឱ្យមានតុល្យភាពជាមួយនឹងរបៀបវារៈដ៏គ្រោះថ្នាក់របស់លោក Trump។

ប្រសិនបើពលរដ្ឋនៅរដ្ឋ California មិនធ្វើសកម្មភាពក្នុងពេលនេះទេ Donald Trump លោកត្រាំនឹងច្បាមយកអំណាចទាំងស្រុងរយៈពេលពីរឆ្នាំទៀត។ សំណើទី 50 ច្បាប់ស្តីពីការឆ្លើយតបនឹងការលួចបន្លំសន្លឹកឆ្នោត នឹងបញ្ឈប់ផែនការប្រឆាំងនឹងប្រជាធិបតេយ្យរបស់ពួកគេ។ ទាំងនេះគឺជាវិធានការ។

- *ធ្វើឱ្យការប្រកួតមានភាពយុត្តិធម៌។* សំណើទី 50 ធានាថាការបោះឆ្នោតពាក់កណ្តាលអាណត្តិឆ្នាំ 2026 ត្រូវបានធ្វើឡើងដោយឈរលើការប្រកួតប្រកបដោយយុត្តិធម៌ដោយគ្មានការផ្តល់ប្រយោជន៍ដោយអយុត្តិធម៌ទៅដល់គណបក្សសាធារណរដ្ឋ។
- *ប្តេជ្ញាចិត្តចំពោះការបែងចែកតំបន់តំណាងសភាដោយយុត្តិធម៌។* សំណើទី 50 អះអាងឡើងវិញនូវការប្តេជ្ញារបស់រដ្ឋ California ចំពោះការបែងចែកតំបន់តំណាងសភាដោយឯករាជ្យ និងអំពាវនាវឱ្យមានការប្តេជ្ញានៅទូទាំងរដ្ឋចំពោះផែនទីប្រកបដោយត្តិធម៌ និងមិនលម្អៀង។
- *ផ្តល់អំណាចដល់អ្នកបោះឆ្នោត។* សំណើទី 50 ផ្តល់អំណាចដល់ពលរដ្ឋនៅរដ្ឋ California មិនមែនអ្នកនយោបាយខាងក្រោយទេ ដើម្បីអនុម័តផែនទីតំបន់តំណាងសភាបន្ទាន់ ដើម្បីឆ្លើយតបនឹងផែនការលួចបន្លំសន្លឹកឆ្នោតរបស់លោកត្រាំ។
- *មានភាពយុត្តិធម៌ និងសមស្រប។* សំណើទី 50 ផ្តល់នូវផែនទីបន្ទាន់ដោយសារតែគណបក្សសាធារណរដ្ឋបន្តការច្បាមយកអំណាយតែប៉ុណ្ណោះ។
- *ជាបណ្តោះអាសន្ន។* ផែនទីទាំងនេះនឹងផុតកំណត់នៅឆ្នាំ 2030។ សំណើទី 50 រក្សានូវកំណែទម្រង់នៃការបែងចែកតំបន់តំណាងសភាឈានមុខគេរបស់រដ្ឋ California និងអះអាងឡើងវិញនូវសមត្ថកិច្ចរបស់គណៈកម្មការបែងចែកតំបន់តំណាងសភាសារឡើងវិញរបស់ពលរដ្ឋនៅរដ្ឋ California ក្នុងការគូសតំបន់តំណាងសភា នៅក្រោយជំរឿនបន្ទាប់។

ការប្រថុយមិនត្រូវខ្ពស់ជាងទេ។ ប្រសិនបើគណបក្សសាធារណរដ្ឋលួចបន្លំការបោះឆ្នោត និងលួចគ្រប់គ្រងសភានៅឆ្នាំក្រោយ ពួកគេនឹងបន្តលុបបំបាត់ការថែទាំសុខភាពសម្រាប់ពលរដ្ឋអាមេរិករាប់លានអ្នក កាត់បន្ថយការផ្តល់មូលនិធិដល់សាលា និងកាត់ចោលនូវសេវាកម្មសំខាន់ៗសម្រាប់អតីតយុទ្ធជន ដើម្បីផ្តល់ជាការអនុគ្រោះពន្ធសម្រាប់មហាសេដ្ឋី និងសាជីវកម្មធំៗ។

*ការពារប្រជាធិបតេយ្យនៅក្នុងរដ្ឋទាំង 50*

រដ្ឋ California មានកាតព្វកិច្ចការពារប្រជាធិបតេយ្យ។ ដើម្បីដូច្នេះបាន យើងមិនអាចទម្លាក់អាវុធ ឬប្រយុទ្ធដោយចងដៃទាំងពីរនៅក្រោយបានទេ។ នៅពេលលោក Trump ព្យាយាមលួចបន្លំសន្លឹកឆ្នោត យើងត្រូវតែប្រឆាំងតបតដោយប្រើឧបករណ៍ទាំងឡាយដែលមាន។

សំណើទី 50 គូសផែនទីប្រកបដោយយុត្តិធម៌ដែលតំណាងឱ្យសហគមន៍ចម្រុះរបស់រដ្ឋ California និងធានាថាសំឡេងរបស់យើងមិនត្រូវបានបំបិទដោយគណបក្សនយោបាយដែលកាន់តំណែងនៅក្នុងរដ្ឋផ្សេងទៀតឡើយ។

California នាំមុខគេនៅក្នុងប្រទេសក្នុងការការពារសិទ្ធិបោះឆ្នោត និងការបោះឆ្នោតដោយយុត្តិធម៌។ នៅពេលដែលរដ្ឋផ្សេងទៀតព្យាយាមបំបិទសំឡេងរបស់យើង និងបន្លំប្រព័ន្ធ យើងត្រូវឆ្លើយតបយ៉ាងម៉ឺងម៉ាត់។

ចូលរួមជាមួយអតីតប្រធានាធិបតី លោក Barack Obama, អភិបាលរដ្ឋ លោក Gavin Newsom, សមាជិកព្រឹទ្ធសភា លោក Alex Padilla, សមាជិកព្រឹទ្ធសភា លោក Adam Schiff, អតីតប្រធានសភា Emerita អ្នកស្រី Nancy Pelosi, អ្នកជំនាញខាងការបោះឆ្នោត, សមាជិកគណៈកម្មការបែងចែកមណ្ឌលឯករាជ្យ, អង្គការ Planned Parenthood, អង្គការ NAACP, អតីតយុទ្ធជនរដ្ឋ California, គ្រូបង្រៀន, និងគិលានុបដ្ឋាយិកា។

បោះឆ្នោត គាំទ្រ នៅលើ សំណើទី. 50 ដើម្បីបញ្ឈប់គម្រោងការក្លែងបន្លំការបោះឆ្នោតរបស់លោក លោក Trump។

បោះឆ្នោត គាំទ្រ ដើម្បីតុល្យភាពនៃអំណាច។

បោះឆ្នោត គាំទ្រ ដើម្បីការពារលទ្ធិប្រជាធិបតេយ្យនៅទូទាំង 50 រដ្ឋ។

**អភិបាល Gavin Newsom**

**សមាជិកព្រឹទ្ធសភាអាមេរិក លោក Alex Padilla**

**អតីតប្រធានសភាអាមេរិក អ្នកស្រី Emerita Nancy Pelosi**

## ★ ការបដិសេធចំពោះទឡ្ហីករណ៍ដែលគាំទ្រសំណើទី 50 ★

ផ្លូវខុស—មិនមាននៅលើ គ្មាននៅលើសំណើទី 50

យើងដឹងថាលទ្ធិប្រជាធិបតេយ្យរបស់អាមេរិកកំពុងឆាបឆេះ ប៉ុន្តែការកំណត់រង្វង់បោះឆ្នោតតាមទំនើងចិត្ត គឺគ្រាន់តែចាក់សាំងបន្ថែមទៀតប៉ុណ្ណោះ! អ្នកនយោបាយទាំងឡាយកំពុងតែឆ្លៀតឱកាសពីវិបត្តិនេះដើម្បីដណ្តើមអំណាច។

សំណើទី 50 មិនការពារលទ្ធិប្រជាធិបតេយ្យរបស់យើងទេ

សំណើទី 50 មិនមែនជាថ្នាំវេទមន្តដែលអាចព្យាបាលបញ្ហារបស់ប្រទេសជាតិបានទេ។ វាអះអាងថាការពារលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបែរជាកាត់បន្ថយសំឡេងរបស់សហគមន៍យើង និងគ្មានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរំលោភអំណាចរបស់ប្រធានាធិបតីឡើយ។ បោះឆ្នោត មិនគាំទ្រ។

ការបន្លំរង្វង់បោះឆ្នោតនៅរដ្ឋ California បានអនុញ្ញាតឱ្យសភានីតិប្បញ្ញត្តិគូសបែងចែកអាសនៈតាមបក្ស ដោយគ្មានតម្លាភាព ឬការចូលរួមពីពលរដ្ឋ ហើយគ្រាន់តែដើម្បីការពារអ្នកកាន់តំណែងបច្ចុប្បន្នប៉ុណ្ណោះ។ ត្រឹមឆ្នាំ 2001 រដ្ឋាភិបាលមានភាពជាប់គាំង ដោយអ្នកនីតិប្បញ្ញត្តិត្រូវជាប់ជាចំណាប់ខ្មាំងដល់ក្រុមជ្រុលនិយមនៃគណបក្សរបស់ពួកគេ។

អ្នកបោះឆ្នោតបានក្រោកឈរឡើង ហើយបានប្រគល់កិច្ចសម្របសម្រួលការកំណត់ព្រំដែនទៅឱ្យពលរដ្ឋ ដែលបណ្តាលឱ្យ៖

- *មណ្ឌលបោះឆ្នោតដែលមានការប្រកួតប្រជែង៖* អាសនៈដែលធ្លាប់មានសុវត្ថិភាព ឥឡូវនេះត្រូវតែទទួលបានដោយការប្រកួតប្រជែងដើម្បីឈ្នះ។
- *តំណាងកាន់តែប្រសើរ៖* ចំនួនស្ត្រីក្នុងសភានីតិប្បញ្ញត្តិបានកើនឡើងទ្វេដង ចំនួនតំណាងជនជាតិអាស៊ីបានកើនឡើងបីដង ចំនួនតំណាងជនជាតិស្បែកខ្មៅបានកើនឡើងជិតទ្វេដង និងអាសនៈសម្រាប់ជនជាតិឡាទីនបានកើនឡើង 8%។
- *រដ្ឋាភិបាលសម្រាប់ប្រជាជន៖* ជាមួយនឹងតំណាងរាស្ត្រមធ្យមច្រើនឡើង នីតិប្បញ្ញត្តិបានអនុម័តច្បាប់ដែលមានការគាំទ្រពីគណបក្សទាំងពីរ ដោយធ្វើការដើម្បីផលប្រយោជន៍របស់ប្រជាជន California ទាំងអស់។

យើងជាប្រជាជន

មណ្ឌលបោះឆ្នោតមិនមែនជារបស់គណបក្សណាមួយទេ វាជារបស់ប្រជាជន។ ប៉ុន្តែ មេគណបក្សចង់ត្រឡប់មកក្តោបក្តាប់អំណាចវិញម្តងទៀត។ ទេ ចំពោះប្រព័ន្ធ “បង់លុយដើម្បីទទួលបានឱកាស”។

សំណើ 50 និយាយថា នេះគឺ “បណ្តោះអាសន្ន” ប៉ុន្តែសភានីតិប្បញ្ញត្តិអាចនឹងឆ្លងកាត់គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋម្តងទៀតនៅឆ្នាំ 2028, 2030—និងប្រហែលជាបន្តទៅមុខទៀត។ កុំចាញ់បោកអី។

អ្នកតាក់តែងច្បាប់បានគូសផែនទីនេះដោយសម្ងាត់ ដើម្បីឱ្យអ្នកយល់ព្រមតាមដោយគ្មានការពិចារណា។ វាមិនមែនជាជម្រើសរបស់អ្នកទេ។

*បោះឆ្នោត មិនគាំទ្រ លើការបន្លំរង្វង់បោះឆ្នោតតាមបក្ស។ បោះឆ្នោត មិនគាំទ្រ លើសំណើ 50។*

**Cynthia Dai,** ប្រធានប្តូរវេន
គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋទីមួយ

**Jeanne Raya,** ប្រធានប្តូរវេន
គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋទីមួយ

**Jodie Filkins Webber,** ប្រធានប្តូរវេន
គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋទីមួយ


ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយឡើយ។

## ★ ទឡ្ហីករណ៍ប្រឆាំងនឹងសំណើ 50 ★

សំណើ 50៖ ការដណ្តើមអំណាចដោយអ្នកនយោបាយ

សំណើ 50 ត្រូវបានសរសេរដោយអ្នកនយោបាយសម្រាប់អ្នកនយោបាយ។ សំណើ 50 រំលាយការការពារតាមរដ្ឋធម្មនុញ្ញ ដែលរក្សាផែនទីបោះឆ្នោតឱ្យមានភាពត្រឹមត្រូវ។ វាដកចេញនូវតម្រូវការដើម្បីរក្សាទីក្រុង ខោនធី និងសហគមន៍មូលដ្ឋានឱ្យនៅរួមគ្នា ហើយលុបបំបាត់ការការពារអ្នកបោះឆ្នោតដែលហាមឃាត់ផែនទីដែលគូសឡើងដើម្បីពេញចិត្តអ្នកកាន់តំណែង ឬគណបក្សនយោបាយ—ដាក់អ្នកនយោបាយឱ្យត្រឡប់មកទទួលខុសត្រូវលើការគូសរង្វង់បោះឆ្នោតរបស់ពួកគេវិញ ឬរបស់មិត្តភ័ក្តិរបស់ពួកគេ។

ការបោះឆ្នោត “មិនគាំទ្រ” ការពារការបោះឆ្នោតត្រឹមត្រូវ និងរក្សាប្រជាជន California មិនមែនអ្នកនយោបាយ ឱ្យបន្តទទួលបន្ទុកលើការបែងចែកមណ្ឌលបោះឆ្នោត។

មិនគាំទ្រលើសំណើ 50៖ វាលុបចោលកំណែទម្រង់ការបោះឆ្នោតដ៏សំខាន់ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត

អស់រយៈពេលជាច្រើនទសវត្សរ៍ អ្នកនយោបាយនៅក្រុង Sacramento បានគូសព្រំប្រទល់មណ្ឌលរបស់ពួកគេដោយសម្ងាត់ ដោយគ្មានការត្រួតពិនិត្យពីសាធារណជន—ធានាការជាប់ឆ្នោតឡើងវិញរបស់ពួកគេ បដិសេធជម្រើសពិតប្រាកដសម្រាប់អ្នកបោះឆ្នោត និងបិទទ្វារមិនឱ្យស្ត្រី និងជនជាតិស្បែកពណ៌ជាច្រើនរូបអាចជាប់ឆ្នោត។

ក្នុងឆ្នាំ 2008 អ្នកបោះឆ្នោតនៅរដ្ឋ California បានអនុម័តកំណែទម្រង់ការបោះឆ្នោតជាប្រវត្តិសាស្ត្រដោយបានបង្កើតគណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋ California។ អ្នកបោះឆ្នោតបានសម្រេចថា ព្រំប្រទល់មណ្ឌលគួរតែគូសដោយគណៈកម្មការដែលមានតុល្យភាពនៃពលរដ្ឋទូទៅ—មិនមែនដោយអ្នកនយោបាយដែលទទួលបានផលប្រយោជន៍នោះទេ។

សំណើ 50 បោះចោលផែនទីសភាអាមេរិកដែលគូសដោយពលរដ្ឋ ដែលត្រូវបានបង្កើតឡើងតាមរយៈដំណើរការសាធារណៈប្រកបដោយតម្លាភាព ដោយមានការបញ្ចូលមតិយោបល់ពីប្រជាជន Californians ជាង 35,000 នាក់។ ផ្ទុយទៅវិញ អ្នកនយោបាយបានគូសផែនទីដោយសម្ងាត់—ទុកឱ្យអ្នកបោះឆ្នោតគ្មានសិទ្ធិនិយាយពិតប្រាកដ។

មិនគាំទ្រ ចំពោះសំណើ 50៖ គម្រោងមួយទៀតដើម្បីបញ្ចប់ជាអចិន្ត្រៃយ៍នូវការបែងចែកមណ្ឌលឯករាជ្យ

ក្នុងឆ្នាំ 2008 និង 2010 គណបក្សប្រជាធិបតេយ្យ និងក្រុមផលប្រយោជន៍បានចំណាយលុយរាប់លានដុល្លារដើម្បីបញ្ឈប់ការបែងចែកមណ្ឌលដោយពលរដ្ឋ។ ក្រោយមក គណបក្សសាធារណរដ្ឋរដ្ឋកាលីហ្វ័រញ៉ាថែមទាំងបានប្តឹងដើម្បីជំរាបការគូសផែនទីដោយពលរដ្ឋ—រដ្ឋ California ក្តី។ ឥឡូវនេះ អ្នកនយោបាយនៅក្រុង Sacramento កំពុងរៀបគម្រោងដើម្បីដណ្តើមអំណាចគ្រប់គ្រងវិញជាមួយសំណើ 50។

កុំយល់ច្រឡំ៖ សំណើ 50 មិនមែនជាបណ្តោះអាសន្នទេ។ អស់រយៈពេលជាងកន្លះទសវត្សរ៍ អ្នកនយោបាយនឹងអាចដាក់ផែនទីបែងចែកមណ្ឌលរបស់ពួកគេដែលបានបន្លំ។ អាក្រក់ជាងនេះទៅទៀត វាបង្កើតជាគំរូដ៏គ្រោះថ្នាក់មួយ—បើកផ្លូវឱ្យក្រុង Sacramento បន្តគូសផែនទីបោះឆ្នោតលើសពីឆ្នាំ 2031—ផ្តល់ឱ្យអ្នកនយោបាយនូវអំណាចអចិន្ត្រៃយ៍ ដើម្បីការពារខ្លួននិងសម្ព័ន្ធមិត្តរបស់ពួកគេពីការទទួលខុសត្រូវចំពោះការចំណាយខ្ពស់ក្នុងការរស់នៅ រួមទាំងថ្លៃផ្ទះឡើងថ្លៃ និងវិក្កយបត្រថាមពលដែលកើនឡើងនៅរដ្ឋ California។

មិនគាំទ្រលើសំណើ 50៖ កុំចាញ់បោកដោយសារការបង្វិលនយោបាយ

អ្នកនយោបាយដែលធ្លាប់ប្រឆាំងនឹងការបែងចែកមណ្ឌលឯករាជ្យពីដំបូង ឥឡូវនេះអះអាងថាសំណើលេខ 50 នឹង “ជួយសង្គ្រោះលទ្ធិប្រជាធិបតេយ្យ”។ តាមពិតទៅ សំណើ 50 ធ្វើឱ្យតំណាងដ៏ត្រឹមត្រូវចុះខ្សោយដោយបិទទ្វារមិនឱ្យសាធារណជនចូលរួម និងនាំយកការបន្លំរង្វង់បោះឆ្នោតត្រឡប់មកកាន់រដ្ឋ California វិញ។

សំណើ 50 មិនមែនជាលទ្ធិប្រជាធិបតេយ្យទេ វាផ្តល់ឱ្យអ្នកបោះឆ្នោតនូវការសម្រេចចិត្តបែប 'យក ឬក៏បោះបង់ចោល' លើផែនទីដែលមានលក្ខណៈបក្សពួកបំផុតក្នុងប្រវត្តិសាស្ត្ររដ្ឋ California—ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងសម្ងាត់នៅពីក្រោយឆាករបស់ក្រុមអ្នកនយោបាយ ដោយគ្មានការចូលរួមពីសាធារណជនទាល់តែសោះ។

សំណើ 50 បែងចែកសហគមន៍ដើម្បីផលប្រយោជន៍អ្នកនយោបាយ ដោយបំបែកខោនធី 114 ដង និងបំបែកទីក្រុង 141 ដង—ច្រើនជាងផែនទីដែលគូសដោយពលរដ្ឋទៅទៀត។

*“នៅពេលដែលអ្នកនយោបាយបន្លំរង្វង់បោះឆ្នោត ពួកគេបំបែកសង្កាត់របស់យើង និងធ្វើឱ្យសំឡេងរបស់សហគមន៍ជនជាតិស្បែកពណ៌ចុះខ្សោយ។ ទោះមានអ្វីកើតឡើងនៅរដ្ឋ Texas ក៏ដោយ យើងមិនអាចសង្គ្រោះលទ្ធិប្រជាធិបតេយ្យដោយបំផ្លាញវានៅរដ្ឋ California បានទេ។ បោះឆ្នោត មិនគាំទ្រ លើសំណើ 50.”—Reverend Mac Shorty, មេដឹកនាំសិទ្ធិពលរដ្ឋ*

*មិនគាំទ្រ លើសំណើ* 50៖: ការខ្ជះខ្ជាយលុយពន្ធដាររបស់ប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់

សភានីតិប្បញ្ញត្តិបានកោះហៅការបោះឆ្នោតពិសេសគ្រាន់តែដើម្បីអនុម័តការកែប្រែរដ្ឋធម្មនុញ្ញដែលការពារអ្នកនយោបាយ—ដែលចំណាយប្រាក់ពន្ធដាររបស់ប្រជាជនអស់ $200,000,000។

ដោយសារតែឱនភាពថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ អ្នកនយោបាយនៅក្រុង Sacramento កំពុងធ្វើការកាត់បន្ថយដ៏លំបាកទៅលើវិស័យសុខាភិបាល លំនៅឋាន ការអប់រំ និងសន្តិសុខសាធារណៈ។ ជំនួសឱ្យការការពារកម្មវិធីសំខាន់ៗ ពួកគេកំពុងតែចំណាយលុយនោះលើការដណ្តើមអំណាចនយោបាយ។

បោះឆ្នោត មិនគាំទ្រ លើសំណើ 50។

*VotersFIRSTAct.org*

**Roberto Moncada**, សមាជិកក្រុមប្រឹក្សាភិបាល
ចលនាជនជាតិឡាទីនរួបរួម

**Faith Bautista Tamashiro**, ប្រធាន
សម្ព័ន្ធជាតិដើម្បីភាពចម្រុះ

**Taylor Shorty**, សមាជិកក្រុមប្រឹក្សាភិបាល
ចលនាផ្តល់អំណាចឡើងវិញដល់សហគមន៍

## ★ ការឆ្លើយបដិសេធចំពោះទឡ្ហីករណ៍ប្រឆាំងនឹងសំណើ 50 ★

*ការព្រមាន៖ មិនគាំទ្រ លើសំណើ 50 គឺត្រូវបានគាំទ្រដោយក្រុមជ្រុលនិយមរបស់លោកលោក* Trump តើនរណាចំណាយលុយរាប់លានប្រឆាំងនឹងសំណើ 50?

មហាសេដ្ឋីប្រឆាំងនឹងសិទ្ធិជ្រើសរើស លោក Charles Munger Jr. ដែលចង់ជួយលោក Donald Trump លោកត្រាំនិងគណបក្សសាធារណរដ្ឋនៅរដ្ឋក្រហម ឱ្យរៀបចំលទ្ធផលបោះឆ្នោតឆ្នាំ 2026 និងប្រគល់អំណាចគ្មានដែនកំណត់ឱ្យលោកលោក Trump សម្រាប់រយៈពេលពីរឆ្នាំទៀត។

គណៈកម្មការបែងចែកមណ្ឌលឯករាជ្យ អ្នកជំនាញផ្នែកការបោះឆ្នោត និងអង្គការសិទ្ធិពលរដ្ឋឈានមុខគេ—ចាប់ពីអង្គការ NAACP រហូតដល់គណៈកម្មាធិការបែងចែកមណ្ឌលតាមបែបប្រជាធិបតេយ្យជាតិ—អំពាវនាវឱ្យអ្នកបដិសេធចំពោះការកុហកដែលផ្សព្វផ្សាយដោយក្រុមបិទមុខក្លែងក្លាយរបស់ក្រុមមិនគាំទ្រលើសំណើ 50។

*ការកុហក #1៖ “សំណើ 50 លុបចោលកំណែទម្រង់ការបោះឆ្នោតដ៏សំខាន់ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត។”* នេះគឺជាការមិនពិតទាំងស្រុង។ សំណើ 50 អំពាវនាវឱ្យរដ្ឋទាំងអស់បញ្ចប់ការបន្លំរង្វង់បោះឆ្នោតតាមបក្ស និងបញ្ជាក់ឡើងវិញនូវអំណាចរបស់គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋនៃរដ្ឋ California ដើម្បីគូសព្រំប្រទល់បោះឆ្នោតបន្ទាប់ពីជំរឿនលើកក្រោយ។

*ការកុហក #2៖ “Prop. 50 ដកចេញនូវតម្រូវការដើម្បីរក្សាទីក្រុង ស្រុក និងសហគមន៍មូលដ្ឋានឱ្យនៅរួមគ្នា។”* សំណើ 50 ធ្វើផ្ទុយពីនេះ ដោយរក្សាទីក្រុង ស្រុក និងសហគមន៍ឱ្យនៅរួមគ្នាច្រើនជាងផែនទីដែលមានស្រាប់របស់រដ្ឋ California ទៅទៀត។

*ការកុហក #3៖ “សំណើ 50 ដាក់អ្នកនយោបាយឱ្យត្រឡប់មកទទួលខុសត្រូវលើការគូសរង្វង់បោះឆ្នោតរបស់ពួកគេវិញ។”* នេះមិនពិតទេ។ សំណើ 50 ផ្តល់អំណាចក្នុងការអនុម័តផែនទីបន្ទាន់ដល់ដៃអ្នកបោះឆ្នោត មិនមែនដល់អ្នកនយោបាយនោះទេ។

*ការកុហក #4៖ “សំណើ 50 បញ្ចប់ជាអចិន្ត្រៃយ៍នូវការបែងចែកមណ្ឌលឯករាជ្យ។”* នេះក៏មិនពិតដែរ។ សំណើ 50 គឺជាដំណោះស្រាយបណ្តោះអាសន្ន និងសមាមាត្រទៅនឹងគម្រោងរៀបចំលទ្ធផលបោះឆ្នោតរបស់លោកលោក Trump ហើយនឹងផុតកំណត់នៅឆ្នាំ 2030។

ប្រជាជន Californiaមិនអាចអនុញ្ញាតឱ្យលោក Donald Trump លោកត្រាំនិងគណបក្សសាធារណរដ្ឋរដ្ឋ Texas រៀបចំលទ្ធផលបោះឆ្នោតឆ្នាំ 2026 និងបំបិទសំឡេងរបស់យើងបានឡើយ។

បោះឆ្នោតគាំទ្រលើសំណើ 50។

ការពារលទ្ធិប្រជាធិបតេយ្យ រក្សាការបែងចែកមណ្ឌលមិនលម្អៀងខាងបក្ស និងធានាការបោះឆ្នោតត្រឹមត្រូវនៅក្នុងរដ្ឋទាំង 50។

**Sara Sadhwani,** សមាជិកគណៈកម្មការ
គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋ California 2020

**Jodi Hicks**, ប្រធាន
សាខាភាពជាមាតាបិតាតាមផែនការរដ្ឋ California

**Nikki Davis Milevsky,** ប្រធាន
សមាគមគ្រូបង្រៀនទីក្រុង Sacramento

50

# សំណើ 50

វិសោធនកម្មនេះដែលស្នើឡើងដោយវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋសភាលេខ 8 នៃសម័យប្រជុំធម្មតាឆ្នាំ 2025–2026 (ជំពូកដំណោះស្រាយលេខ 156 ច្បាប់ស្ដីពីលក្ខន្តិកៈឆ្នាំ 2025) កែប្រែរដ្ឋធម្មនុញ្ញ California ដោយបន្ថែមផ្នែកថ្មីមួយទៅក្នុងនោះ។ ដូច្នេះហើយ បទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ព*អក្សរទ្រេត* ដើម្បីបង្ហាញថាវាជាផ្នែកថ្មី។

## វិសោធនកម្មស្នើឡើងចំពោះមាត្រា XXI

ទីមួយ—វិធានការនេះនឹងត្រូវបានគេស្គាល់ ហើយអាចត្រូវបានលើកឡើង ជា "ច្បាប់ស្ដីពីការឆ្លើយតបចំពោះការរៀបចំលទ្ធផលបោះឆ្នោត"។

ទីពីរ—ប្រជាជននៃរដ្ឋ California រកឃើញ និងប្រកាសនូវអ្វីៗទាំងអស់ដូចខាងក្រោម៖

(a) ប្រធានាធិបតី លោក Donald Trump បានអំពាវនាវឱ្យរដ្ឋដែលដឹកនាំដោយគណបក្សសាធារណរដ្ឋធ្វើការបែងចែកមណ្ឌលសភានៅពាក់កណ្ដាលអាណត្តិដែលមិនធ្លាប់មានពីមុនមក ដើម្បីរៀបចំលទ្ធផលនៃការបោះឆ្នោតពាក់កណ្ដាលអាណត្តិរបស់សហរដ្ឋអាមេរិកឆ្នាំ 2026 មុនពេលការបោះឆ្នោតចាប់ផ្ដើម។

(b) រដ្ឋ Texas បានកោះប្រជុំពិសេសនៃស្ថាប័ននីតិប្បញ្ញត្តិរបស់ខ្លួន ដើម្បីគូសផែនទីមណ្ឌលសភាថ្មី ដើម្បីផ្តល់អត្ថប្រយោជន៍មិនត្រឹមត្រូវដល់គណបក្សសាធារណរដ្ឋ។

(c) សភានីតិប្បញ្ញត្តិនៃរដ្ឋ Florida បានបង្កើតគណៈកម្មាធិការជ្រើសរើសមួយដើម្បីជំរុញការបែងចែកមណ្ឌលនៅពាក់កណ្ដាលអាណត្តិដែលមិនធ្លាប់មានពីមុនមក ដើម្បីផ្តល់អត្ថប្រយោជន៍មិនត្រឹមត្រូវដល់គណបក្សសាធារណរដ្ឋ។

(d) គណបក្សសាធារណរដ្ឋបានអំពាវនាវឱ្យរដ្ឋ Ohio ធ្វើការបែងចែកមណ្ឌលនៅពាក់កណ្ដាលអាណត្តិ ដើម្បីបង្កើតកៅអីសភាសម្រាប់គណបក្សសាធារណរដ្ឋឱ្យបានកាន់តែច្រើនដោយមិនត្រឹមត្រូវ។

(e) មន្ត្រីគណបក្សសាធារណរដ្ឋនៅក្នុងរដ្ឋ Indiana, Missouri, New Hampshire, Nebraska, និង South Carolina ក៏កំពុងពិចារណាលើការអំពាវនាវរបស់ប្រធានាធិបតី លោក Trump សម្រាប់ការបែងចែកមណ្ឌលសភានៅពាក់កណ្ដាលអាណត្តិ ដើម្បីផ្តល់អត្ថប្រយោជន៍មិនត្រឹមត្រូវដល់គណបក្សសាធារណរដ្ឋផងដែរ។

(f) លោកប្រធានាធិបតី Trump និងគណបក្សសាធារណរដ្ឋកំពុងព្យាយាមដណ្ដើមយកអាសនៈគ្រប់គ្រាន់តាមរយៈការបែងចែកមណ្ឌល ដើម្បីរៀបចំលទ្ធផលនៃការបោះឆ្នោតពាក់កណ្ដាលអាណត្តិរបស់សហរដ្ឋអាមេរិកឆ្នាំ 2026 ដោយមិនគិតពីរបៀបដែលប្រជាជនបោះឆ្នោតនោះទេ។

(g) គម្រោងរៀបចំលទ្ធផលបោះឆ្នោតរបស់លោកប្រធានាធិបតី Trump គឺជាភាពអាសន្នសម្រាប់លទ្ធិប្រជាធិបតេយ្យរបស់យើង។

(h) ការបោះឆ្នោតពាក់កណ្ដាលអាណត្តិរបស់សហរដ្ឋអាមេរិកឆ្នាំ 2026 គឺជាឱកាសតែមួយគត់សម្រាប់អ្នកបោះឆ្នោតក្នុងការផ្ដល់នូវការត្រួតពិនិត្យ និងតុល្យភាពដ៏សំខាន់ប្រឆាំងនឹងរបៀបវារៈដ៏គ្រោះថ្នាក់របស់ប្រធានាធិបតី Trump។

(i) California បានឈរជាអ្នកដឹកនាំថ្នាក់ជាតិយូរមកហើយសម្រាប់ការបែងចែកមណ្ឌលដោយយុត្តិធម៌ ឯករាជ្យ និងមិនលម្អៀងខាងបក្ស។

(j) California អំពាវនាវឱ្យរដ្ឋផ្សេងទៀតទាំងអស់ប្ដេជ្ញាចំពោះការគូសផែនទីដោយយុត្តិធម៌ និងមិនលម្អៀង។

(k) California មានកាតព្វកិច្ចការពារលទ្ធិប្រជាធិបតេយ្យ។

(*l*) ការបោះឆ្នោតពាក់កណ្ដាលអាណត្តិរបស់សហរដ្ឋអាមេរិកឆ្នាំ 2026 សម្រាប់សភាត្រូវតែប្រព្រឹត្តទៅដោយស្មើភាពគ្នា ដោយគ្មានអត្ថប្រយោជន៍ដ៏ខ្លាំងក្លា និងមិនត្រឹមត្រូវសម្រាប់គណបក្សសាធារណរដ្ឋនោះទេ។

(m) ពលរដ្ឋនៅរដ្ឋ California មិនមែនអ្នកនយោបាយខាងក្រោយទេ ដើម្បីអនុម័តផែនទីតំបន់តំណាងសភាបន្ទាន់ ដើម្បីឆ្លើយតបនឹងផែនការលួចបន្លំសន្លឹកឆ្នោតរបស់លោក Trump។

(n) នេះគឺជាចេតនារបស់ប្រជាជនដែលថាផែនទីបណ្ដោះអាសន្នរបស់រដ្ឋ California ត្រូវបានរចនាឡើងដើម្បីបន្សាបការបន្លំសន្លឹកឆ្នោតតាមបក្សដែលកំពុងតែត្រូវបានគំរាមកំហែងដោយរដ្ឋដែលដឹកនាំដោយគណបក្សសាធារណរដ្ឋ ដោយមិនធ្វើឱ្យប៉ះពាល់ដល់តំណាងដ៏ត្រឹមត្រូវសម្រាប់សហគមន៍ទាំងអស់នោះទេ។

ទីបី—ថាមាត្រា 4 ត្រូវបានបន្ថែមទៅមាត្រាទី XXI នៃរដ្ឋធម្មនុញ្ញនោះ ដើម្បីមានខ្លឹមសារដូចតទៅ៖

*ចំណុច 4. (a) វាគឺជាគោលនយោបាយរបស់រដ្ឋ California ក្នុងការគាំទ្រការប្រើប្រាស់គណៈកម្មការបែងចែកមណ្ឌលដែលមានយុត្តិធម៌ ឯករាជ្យ និងមិនចូលខាងគណបក្សណាមួយ នៅទូទាំងប្រទេស។ ប្រជាជននៃរដ្ឋ California អំពាវនាវឱ្យសភាអាមេរិកអនុម័តច្បាប់សហព័ន្ធ និងស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកដើម្បីតម្រូវឱ្យមានការប្រើប្រាស់គណៈកម្មការបែងចែកមណ្ឌលដែលមានយុត្តិធម៌ ឯករាជ្យ និងមិនចូលខាងគណបក្សណាមួយ នៅទូទាំងប្រទេស។*

*(b) ដើម្បីឆ្លើយតបទៅនឹងការបែងចែកមណ្ឌលសភាឡើងវិញនៅរដ្ឋ Texas ក្នុងឆ្នាំ 2025 និងទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតនៃរដ្ឋធម្មនុញ្ញនេះ ឬច្បាប់ដែលមានស្រាប់ក៏ដោយ ក៏មណ្ឌលតែមួយសម្រាប់សភាដែលបានឆ្លុះបញ្ចាំងនៅក្នុងវិក័យបត្ររដ្ឋសភាលេខ 604 នៃសម័យប្រជុំធម្មតាឆ្នាំ 2025-26 ស្របតាមតម្រូវការនៃជំពូកទី 5 (ចាប់ពីចំណុច 21400) នៃផ្នែកទី 21 នៃក្រមបោះឆ្នោតនឹងត្រូវបានប្រើប្រាស់បណ្ដោះអាសន្នសម្រាប់ការបោះឆ្នោតសភាគ្រប់ប្រភេទសម្រាប់អាណត្តិដែលចាប់ផ្ដើមនៅ ឬក្រោយកាលបរិច្ឆេទដែលអនុផ្នែកនេះចូលជាធរមាន និងមុនការបញ្ជាក់បន្ទាត់ព្រំដែនសភាថ្មីដែលគូសដោយគណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋ ស្របតាមអនុផ្នែក (d)។*

*(c) (1) អគ្គរដ្ឋអាជ្ញាមានសិទ្ធិស្របច្បាប់តែមួយគត់ក្នុងការការពារសកម្មភាពណាមួយទាក់ទងនឹងផែនទីមណ្ឌលសភាដែលបានអនុម័តស្របតាមអនុផ្នែក (b)។*

*(2) តុលាការកំពូលរដ្ឋ California មានយុត្តាធិការដើម និងផ្ដាច់មុខនៅក្នុងរាល់នីតិវិធីទាំងអស់ដែលផែនទីមណ្ឌលសភាដែលបានអនុម័តស្របតាមអនុផ្នែក (b) ត្រូវបានជំទាស់។*

*(d) គណៈកម្មការបែងចែកមណ្ឌលឯករាជ្យដែលបង្កើតឡើងដោយពលរដ្ឋស្របតាមចំណុច 1 នឹងបន្តធ្វើការកែសម្រួលបន្ទាត់ព្រំដែននៃមណ្ឌលសភា មណ្ឌលព្រឹទ្ធសភា មណ្ឌលសភានីតិប្បញ្ញត្តិ និងមណ្ឌលក្រុមប្រឹក្សាភិបាលសមភាព ស្របតាមស្ដង់ដារ និងដំណើរការដែលបានកំណត់ក្នុងចំណុច 2 ក្នុងឆ្នាំ 2031 និងរៀងរាល់ 10 ឆ្នាំម្ដងចាប់ពីពេលនោះមក ដូចដែលមានចែងក្នុងចំណុច 1។*

ទីបួន—បទប្បញ្ញត្តិរបស់វិធានការនេះអាចបំបែកបាន។ ប្រសិនបើផ្នែកណាមួយ មាត្រាណាមួយ អនុផ្នែកណាមួយ កថាខណ្ឌណាមួយ ឃ្លាណាមួយ ប្រយោគណាមួយ ពាក្យណាមួយ ឬការអនុវត្តណាមួយនៃវិធានការនេះ ត្រូវបានចាត់ទុកថាគ្មានសុពលភាពដោយសារហេតុផលណាមួយដោយសេចក្ដីសម្រេចរបស់តុលាការដែលមានយុត្តាធិការត្រឹមត្រូវនោះ សេចក្ដីសម្រេចនោះនឹងមិនប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសេសសល់នៃវិធានការនេះឡើយ។ សភានីតិប្បញ្ញត្តិសូមប្រកាសថា ខ្លួននឹងស្នើឡើងនូវវិធានការនេះ ហើយអ្នកបោះឆ្នោតសូមប្រកាសថា ពួកគេនឹងអនុម័តវិធានការនេះ និងគ្រប់ផ្នែក មាត្រា អនុផ្នែក កថាខណ្ឌ ឃ្លា ប្រយោគ ពាក្យ និងការអនុវត្តដែលមិនត្រូវបានប្រកាសថាមិនមានសុពលភាព ឬផ្ទុយពីធម្មនុញ្ញ ដោយមិនគិតថាផ្នែកណាមួយនៃវិធានការនេះ ឬការអនុវត្តនៃវិធានការនេះនឹងត្រូវបានប្រកាសថាមិនមានសុពលភាពជាបន្តបន្ទាប់នោះទេ។

# គន្លឹះសម្រាប់យោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសសម្រាប់រដ្ឋ California

ការចូលរួមក្នុងការបោះឆ្នោតគឺមានភាពងាយស្រួលជាងពេលណាទាំងអស់សម្រាប់ប្រជាជន California ដែលបម្រើការក្នុងជួរយោធា ឬ រស់នៅក្រៅសហរដ្ឋអាមេរិក។ វាចាប់ផ្តើមនៅពេលអ្នកចុះឈ្មោះបោះឆ្នោតជាយោធា ឬអ្នកបោះឆ្នោតនៅក្រៅប្រទេស ហើយទទួលបានសម្ភារៈបោះឆ្នោតតាមសំបុត្រ ទូរសារ ឬអ៊ីមែល។ ត្រៀមខ្លួន!

- **ចាប់ផ្តើមមុន។** មន្ត្រីបោះឆ្នោតប្រចាំខោនធីរបស់រដ្ឋ California ត្រូវតែផ្ញើសន្លឹកឆ្នោតទៅកាន់យោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសយ៉ាងយូរត្រឹម 45 ថ្ងៃមុនថ្ងៃបោះឆ្នោត។ បំពេញពាក្យសុំចុះឈ្មោះបោះឆ្នោតមុនម៉ោង *registertovote.ca.gov* ដើម្បីធានាថាអ្នកទទួលបានឯកសារបោះឆ្នោតរបស់អ្នកទាន់ពេល រួចអាចប្រគល់សន្លឹកឆ្នោតរបស់អ្នកវិញនៅមុនថ្ងៃបោះឆ្នោត។
- **ស្វែងយល់ពីជម្រើសរបស់អ្នក។** នៅពេលចុះឈ្មោះបោះឆ្នោតជាយោធា ឬអ្នកបោះឆ្នោតនៅក្រៅប្រទេស អ្នកអាចជ្រើសរើសឱ្យសន្លឹកឆ្នោតរបស់អ្នកផ្ញើតាមសំបុត្រ ទូរសារ ឬអ៊ីមែលមកអ្នក។ លើសពីនេះ អ្នកអាចចូលទៅកាន់វិបសាយថ៍ផ្លូវការរបស់ការបោះឆ្នោតខោនធីរបស់អ្នក សម្រាប់ព័ត៌មានអំពីរបៀបទាញយកសន្លឹកឆ្នោត និងឯកសារបោះឆ្នោតរបស់អ្នក។ អ្នកអាចប្រគល់សន្លឹកឆ្នោតដែលបានបោះឆ្នោតរបស់អ្នកទៅឱ្យមន្ត្រីរៀបចំបោះឆ្នោតខោនធីរបស់អ្នកតាមសំបុត្រ ឬក្នុងកាលៈទេសៈជាក់លាក់ណាមួយ តាមរយៈទូរសារ។ ប្រសិនបើអ្នកបំពេញតាមតម្រូវការក្នុងការប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមទូរសារ អ្នកក៏ត្រូវទូរសារទម្រង់ពាក្យសម្បថអ្នកបោះឆ្នោត (មានពីមន្ត្រីរៀបចំការបោះឆ្នោតខោនធីរបស់អ្នក) ដោយបោះបង់សិទ្ធិរបស់អ្នកក្នុងការបោះឆ្នោតសម្ងាត់។

> **ប្រុងប្រយ័ត្ន!** កម្មវិធីជំនួយការបោះឆ្នោតថ្នាក់សហព័ន្ធ (FVAP) បានបញ្ចប់សេវាកម្ម របស់គេនៃការផ្ញើរតាមទូរសារសម្ភារៈអ្នកបោះឆ្នោតពីយោធានិងនៅបរទេសទៅមន្ត្រីរៀបចំបោះឆ្នោត។
>
> **តើនេះមានន័យដូចម្តេច៖ អ្នកមិនអាចផ្ញើរសន្លឹកបោះឆ្នោតរបស់អ្នកទៅ *fax@fvap.gov* ទៀតឡើយ។**
>
> ប្រសិនបើអ្នកចង់ប្រគល់សន្លឹកឆ្នោតដែលបានបោះរួចតាមរយៈទូរសារ អ្នកត្រូវតែផ្ញើវាដោយផ្ទាល់ទៅមន្ត្រីបោះឆ្នោតប្រចាំខោនធីរបស់អ្នក។

- **រក្សាទំនាក់ទំនង។** នៅពេលដែលអ្នកចុះឈ្មោះជាយោធា ឬអ្នកបោះឆ្នោតនៅក្រៅប្រទេស អ្នកនឹងបន្តទទួលបានសន្លឹកឆ្នោត និងសម្ភារៈបោះឆ្នោតពីមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក មុនពេលការបោះឆ្នោតទូទាំងរដ្ឋនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ អ្នកនឹងត្រូវធ្វើបច្ចុប្បន្នភាពការចុះឈ្មោះបោះឆ្នោតរបស់អ្នកប្រសិនបើអ្នកផ្លាស់ប្តូរអាសយដ្ឋាន ឈ្មោះ ឬចំណូលចិត្តគណបក្សនយោបាយរបស់អ្នក។ ទស្សនា *sos.ca.gov/elections/voter-registration/military-overseas-voters/* សម្រាប់ធនធានការបោះឆ្នោតកាន់តែច្រើនដែលត្រូវបានរចនាឡើងជាពិសេសសម្រាប់អ្នក។

## កាលបរិច្ឆេទដែលត្រូវចងចាំ៖

**ថ្ងៃទី 20 ខែតុលា ឆ្នាំ 2025៖** ថ្ងៃចុងក្រោយសម្រាប់អ្នកបោះឆ្នោតយោធា និងក្រៅប្រទេសក្នុងការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតទូទៅ។

**ថ្ងៃទី 21 ខែតុលា ដល់ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025៖** ការចុះឈ្មោះនៅថ្ងៃតែមួយគឺនៅមាន។ អ្នកអាចចុះឈ្មោះបោះឆ្នោត "ដោយមានលក្ខខណ្ឌ" និងបោះឆ្នោតបណ្តោះអាសន្នក្នុងអំឡុងពេលនេះ។ ទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម ។

**ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025** ថ្ងៃបោះឆ្នោត! ប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ ដរាបណាអ្នកទទួលបានសំបុត្រនោះ។ សន្លឹកឆ្នោតផ្ញើរតាមសំបុត្រត្រូវតែបោះត្រាប្រៃសណីយ៍យ៉ាងយូរត្រឹម និងត្រូវបានការិយាល័យបោះឆ្នោតប្រចាំស្រុករបស់អ្នកទទួលយ៉ាងយូរត្រឹមខែវិច្ឆិកា 12, 2025។ សន្លឹកឆ្នោតដែលផ្ញើតាមទូរសារ ត្រូវតែបញ្ជូនទៅកាន់ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ដោយបិទការបោះឆ្នោតមិនក្រោយពីម៉ោង 8:00 យប់ ម៉ោងស្តង់ដារប៉ាស៊ីហ្វិកនៅថ្ងៃបោះឆ្នោត។

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

រដ្ឋលេខាធិការរដ្ឋ California

(888) 345-4917

*sos.ca.gov/elections/voter-registration/military-overseas-voters/*

កម្មវិធីជំនួយការបោះឆ្នោតសហព័ន្ធ

(800) 438-VOTE (8683)

*www.fvap.gov*

# ការព្រមាន៖ ការទាក់ទាញរកសំឡេងឆ្នោតត្រូវបានហាមឃាត់!

ការបំពានទាំងឡាយអាចនាំឱ្យមានការផាកពិន័យ និង/ឬដាក់ពន្ធនាគារ។

## ទីកន្លែង៖

- នៅក្នុងបរិវេណក្បែរទៅនឹងបុគ្គលដែលតម្រង់ជួរដើម្បីបោះសន្លឹកឆ្នោត ឬនៅក្នុងបរិវេណ 100 ហ្វីតនៃច្រកចូលនៃកន្លែងបោះឆ្នោត កន្លែងបោះឆ្នោតជាយផ្លូវ ឬប្រអប់ទម្លាក់សន្លឹកឆ្នោត ដែលសកម្មភាពទាំងឡាយខាងក្រោមត្រូវបានហាមឃាត់។






## សកម្មភាពផ្សេងៗដែលត្រូវបានហាមឃាត់ ៖

- **មិនត្រូវ** ស្នើសុំឱ្យបុគ្គលបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានសន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** បង្ហាញឈ្មោះ និមិត្តសញ្ញា ឬរូបភាពរបស់បេក្ខជននោះទេ។
- **មិនត្រូវ** រារាំងការចូលប្រើប្រាស់ ឬដើររាវែកនៅក្បែរប្រអប់ទម្លាក់សន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** ផ្តល់ឯកសារ ឬព័ត៌មានជាសំឡេងណាមួយគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាមួយ ឬវិធានការសន្លឹកឆ្នោតនៅក្បែរកន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬប្រអប់ទម្លាក់សន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** ចែកចាយញត្តិទាំងឡាយ រួមបញ្ចូលទាំងសកម្មភាពផ្តួចផ្តើម ការធ្វើប្រជាមតិ ការបោះឆ្នោតដកតំណែង ឬការតែងតាំងបេក្ខជនណាមួយនោះទេ។
- **មិនត្រូវ** ចែកចាយ បង្ហាញ ពាក់សម្លៀកបំពាក់ណាមួយ (មួក អាវ សញ្ញា ឡេវ ស្ទីគ័រ) ដែលមានឈ្មោះ រូបភាព និមិត្តសញ្ញារបស់បេក្ខជន និង/ឬគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានសន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** បង្ហាញព័ត៌មាន ឬនិយាយទៅអ្នកបោះឆ្នោតអំពីសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោតនោះទេ។

សេចក្តីសង្ខេបនៃការហាមឃាត់ចំពោះការធ្វើការអោយអ្នកឈរឈ្មោះបោះឆ្នោត ខាងលើមានចែងនៅក្នុងមាត្រា 7 ជំពូក 4 ផ្នែក 18 នៃក្រមបោះឆ្នោតរដ្ឋ California។

# ការព្រមាន៖ ការប្រព្រឹត្តអំពើពុករលួយក្នុងដំណើរការបោះឆ្នោតត្រូវបានហាមឃាត់!

បុគ្គលដែលបំពាននឹងទទួលការផាកពិន័យ និង/ឬការជាប់ពន្ធនាគារ។

## សកម្មភាពផ្សេងៗដែលត្រូវបានហាមឃាត់ ៖

- **មិនត្រូវ** ប្រព្រឹត្តិ ឬមានបំណងប្រព្រឹត្តិអំពើបន្លំក្នុងការបោះឆ្នោត។
- **មិនត្រូវ** ផ្តល់ប្រភេទនៃសំណង ឬការសូកប៉ាន់ណាមួយ នៅក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយជាការបញ្ចុះបញ្ចូល ឬក្នុងបំណងបញ្ចុះបញ្ចូល ទៅដល់បុគ្គលណាម្នាក់ដើម្បីបោះឆ្នោត ឬមិនឱ្យធ្វើការបោះឆ្នោតឡើយ។
- **មិនត្រូវ** បោះឆ្នោតដោយខុសច្បាប់។
- **មិនត្រូវ** ប៉ុនប៉ងធ្វើការបោះឆ្នោត ឬផ្តល់ការឧបត្ថម្ភដល់អ្នកដទៃទៀតឱ្យធ្វើការបោះឆ្នោតនៅពេលមិនមានសិទ្ធិក្នុងការបោះឆ្នោត។
- **មិនត្រូវ** ចូលរួមក្នុងការធ្វើការអោយអ្នកឈរឈ្មោះបោះឆ្នោតថតរូប ឬកត់ត្រាអ្នកបោះឆ្នោតដែលចូលទៅកាន់ ឬចេញពីទីតាំងមណ្ឌលបោះឆ្នោត ឬរារាំងសកម្មភាពចេញចូល ឬចតរថយន្តនោះទេ។
- **មិនត្រូវ** បង្កផលវិបាកដល់សិទ្ធិបោះឆ្នោតរបស់នរណាម្នាក់ ឬរារាំងនរណាម្នាក់មិនឱ្យធ្វើការបោះឆ្នោត ពន្យារដំណើរការបោះឆ្នោត ឬការផ្តល់យោបល់ដោយការបោកបន្លំដល់បុគ្គលណាមួយថាគាត់មិនមានសិទ្ធិក្នុងការបោះឆ្នោត ឬថាគាត់មិនបានចុះឈ្មោះបោះឆ្នោតឡើយ។
- **មិនត្រូវ** ប៉ុនប៉ងពិនិត្យបញ្ជាក់រកមើលពីរបៀបដែលអ្នកបោះឆ្នោតធ្វើការបោះឆ្នោតនោះទេ។
- **មិនត្រូវ** កាន់កាប់ ឬរៀបចំឱ្យនរណាម្នាក់កាន់កាប់អាវុធនៅក្នុងបរិវេណនៃកន្លែងបោះឆ្នោត លើកលែងតែក្នុងករណីមួយចំនួន។
- **មិនត្រូវ** បង្ហាញខ្លួន ឬរៀបចំឱ្យនរណាម្នាក់បង្ហាញខ្លួនក្នុងឯកសណ្ឋានជាមន្ត្រីរៀបចំសុវត្ថិភាព សន្តិសុខ ឬបុគ្គលិកសន្តិសុខនៅក្នុងបរិវេណនៃកន្លែងបោះឆ្នោត លើកលែងតែក្នុងករណីមួយចំនួន។
- **មិនត្រូវ** ប៉ះពាល់ ឬជ្រៀតជ្រែកជាមួយនឹងសមាសធាតុណាមួយនៃប្រព័ន្ធបោះឆ្នោតនោះទេ។
- **មិនត្រូវ** ក្លែង បន្លំ ឬប៉ះពាល់ទៅលើសន្លឹកឆ្នោតដែលបញ្ជូនត្រលប់មកវិញនោះទេ។
- **មិនត្រូវ** កែប្រែសន្លឹកឆ្នោតដែលបញ្ជូនត្រលប់មកវិញនោះទេ។
- **មិនត្រូវ** ប៉ះពាល់ បំផ្លាញ ឬកែប្រែបញ្ជីបោះឆ្នោតណាមួយ សន្លឹកឆ្នោតផ្លូវការ ឬប្រអប់ដាក់សន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** បង្ហាញប្រអប់ប្រមូលសន្លឹកឆ្នោតមិនផ្លូវការណាមួយដែលអាចបោកបញ្ឆោតអ្នកបោះ ឆ្នោតឱ្យជឿថាវាជាប្រអប់ប្រមូលសន្លឹកឆ្នោតផ្លូវការនោះទេ។
- **មិនត្រូវ** ប៉ះពាល់ ឬជ្រៀតជ្រែកលើច្បាប់ថតចម្លងនៃលទ្ធផលនៃការបោះឆ្នោតនោះទេ។
- **មិនត្រូវ** បង្ខំ ឬបោកបញ្ឆោតនរណាម្នាក់ដែលមិនចេះអក្សរ ឬមនុស្សចាស់ឱ្យធ្វើការបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានដែលផ្ទុយទៅនឹងគោលបំណងរបស់ពួកគេនោះទេ។
- **មិនត្រូវ** ដើរតួជាមន្ត្រីបោះឆ្នោតនៅពេលអ្នកមិនមែនជាមន្ត្រីបោះឆ្នោតនោះទេ។

និយោជក មិនអាចទាមទារ ឬស្នើឱ្យបុគ្គលិករបស់ខ្លួននាំយកសន្លឹកឆ្នោតបោះតាមប្រអប់សំបុត្ររបស់ខ្លួនមកកន្លែងធ្វើការ ឬស្នើឱ្យបុគ្គលិករបស់ខ្លួនបោះឆ្នោតនៅកន្លែងធ្វើការនោះទេ។ នៅពេលបើកប្រាក់បៀវត្ស ឬប្រាក់ឈ្នួល និយោជកមិនអាចភ្ជាប់ឯកសារផ្សេងៗដែលមានបំណងជះឥទ្ធិពលដល់ទស្សនៈ ឬសកម្មភាពនយោបាយរបស់និយោជិតខ្លួននោះទេ។

សមាជិកក្រុមប្រឹក្សាប្រចាំតំបន់ព្រំដែន មិនអាចប៉ុនប៉ងកំណត់ពីរបៀបដែលអ្នកបោះឆ្នោតធ្វើការបោះឆ្នោតនោះទេ ឬប្រសិនបើព័ត៌មាននោះត្រូវបានបើកបង្ហាញ សូមបង្ហាញពីរបៀបដែលអ្នកបោះឆ្នោតទម្លាក់សន្លឹកឆ្នោតរបស់ខ្លួន ។

ការហាមឃាត់លើសកម្មភាពដែលទាក់ទងនឹងអំពើពុករលួយក្នុងដំណើរការបោះឆ្នោតដែលត្រូវបានសង្ខេបខាងលើមានចែងនៅក្នុងជំពូក 6 ផ្នែក 18 នៃក្រមបោះឆ្នោតរដ្ឋ California។

# ស្វែងរកប្រភពព័ត៌មានអំពីការបោះឆ្នោតដែលអាចទុកចិត្តបាន

រដ្ឋលេខាធិការ សូមប្តេជ្ញាធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ សុវត្ថិភាព សន្តិសុខ ភាពត្រឹមត្រូវ និងអាចចូលដំណើរការបាន។ ព័ត៌មានមិនពិតដោយចេតនា ឬផ្សេងក្រៅពីនេះ បន្តបំភាន់អ្នកបោះឆ្នោត និងបង្កើតការមិនទុកចិត្តក្នុងដំណើរការបោះឆ្នោត។ រដ្ឋ California មានកម្មវិធីធ្វើតេស្ត និងបញ្ជាក់ប្រព័ន្ធបោះឆ្នោតដ៏ទូលំទូលាយបំផុតមួយនៅក្នុងប្រទេស។

ការការពារដ៏ល្អបំផុតរបស់យើង ប្រឆាំងនឹងពាក្យចចាមអារ៉ាម និងព័ត៌មានមិនពិតអំពីអ្នក! ព័ត៌មានបោះឆ្នោតក្លែងក្លាយ ជារឿងលើសពីធម្មតាអ្នកគិតទៅទៀត។ ប្រសិនបើការទាមទារមួយ ហាក់ដូចជាខឹងសម្បារ ឬរៀបចំឡើងដើម្បីធ្វើឲ្យអ្នកខកចិត្ត វាប្រហែលជាមិនពិតទេ។

ប្រភពដ៏ល្អបំផុតសម្រាប់ព័ត៌មានអំពីការបោះឆ្នោតដែលអាចទុកចិត្តបាន គឺមន្ត្រីបោះឆ្នោតក្នុងតំបន់ និងរដ្ឋរបស់អ្នក។ ដើម្បីស្វែងយល់បន្ថែមអំពីការពិតអំពីការបោះឆ្នោត ឬពាក្យចចាមអារ៉ាមទូទៅដែលកំពុងរីករាលដាល *សូមចូលទៅកាន់គេហទំព័រ catrustedinformation.sos.ca.gov*។

រាយការណ៍ព័ត៌មានមិនពិតទៅ *votesure@sos.ca.gov*។

# ការការពារសុវត្ថិភាពការបោះឆ្នោតរដ្ឋ California

## បច្ចេកវិទ្យាមានសុវត្ថិភាព

- ប្រព័ន្ធបោះឆ្នោតខោនធី មិនភ្ជាប់ទៅអ៊ីនធឺណិតទេ
- បច្ចេកទេសសន្តិសុខរឹងមាំ ត្រូវបានអនុវត្តជាទៀងទាត់
- ការត្រួតពិនិត្យការគំរាមកំហែងជាប្រចាំ និងការស្កេនភាពងាយរងគ្រោះដោយសហការជាមួយរដ្ឋ និងដៃគូសហព័ន្ធរបស់យើង
- ការធ្វើតេស្តប្រព័ន្ធបោះឆ្នោត និងវិញ្ញាបនបត្រយ៉ាងម៉ត់ចត់ ដែលធ្វើឡើងដោយរដ្ឋលេខាធិការ California
- មានតែបុគ្គលិករៀបចំការបោះឆ្នោតដែលមានការអនុញ្ញាតប៉ុណ្ណោះ ដែលអាចចូលទៅកាន់ប្រព័ន្ធដែលទាក់ទងនឹងតួនាទីរបស់ខ្លួន

## ដំណើរការមានសុវត្ថិភាព

- VoteCal គឺជាមូលដ្ឋានទិន្នន័យចុះឈ្មោះសម្រាប់អ្នកបោះឆ្នោតទូទាំងរដ្ឋដែលមានលក្ខណៈកណ្តាល។ VoteCal ត្រួតពិនិត្យប្រឆាំងនឹងកំណត់ត្រាផ្លូវការ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់
- សន្លឹកឆ្នោត និងបច្ចេកវិជ្ជានៃការបោះឆ្នោត ត្រូវតែប្រកាន់ខ្ជាប់នូវនីតិវិធីស្តីពីការឃុំឃាំងយ៉ាងតឹងរ៉ឹង
- មានសន្លឹកឆ្នោតជាក្រដាស សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់
- សវនកម្មក្រោយការបោះឆ្នោត ធ្វើឡើងដោយមន្ត្រីរៀបចំការបោះឆ្នោត
- ហត្ថលេខាត្រូវបានផ្ទៀងផ្ទាត់នៅលើស្រោមសំបុត្របោះឆ្នោតតាមសំបុត្រទាំងអស់
- ផែនការសង្គ្រោះបន្ទាន់សម្រាប់អគ្គីភ័យ ទឹកជំនន់ ឧបទ្ទវហេតុតាមអ៊ីនធឺណិត និងច្រើនទៀត

## សុវត្ថិភាពទាំងកន្លែង និងសម្រាប់មនុស្ស

- ការគ្រប់គ្រងការចូលប្រើជារូបវ័ន្ត និងសុវត្ថិភាពនៃទីតាំង
- ការវាយតម្លៃសុវត្ថិភាព និងភាពងាយស្រួលត្រូវបានបញ្ចប់សម្រាប់ទីតាំងទាំងអស់
- ប្រអប់ទម្លាក់សន្លឹកឆ្នោត ត្រូវបានធានា និងត្រួតពិនិត្យ
- ដំណើរការបោះឆ្នោត បើកឱ្យមានការសង្កេតក្នុងអំឡុងពេលម៉ោងប្រតិបត្តិការជាក់លាក់
- ការហ្វឹកហ្វឺនការបន្ធូរ និងសុវត្ថិភាពតាមអ៊ីនធឺណិត ត្រូវបានផ្តល់ជូនដល់បុគ្គលិកទាំងអស់

# អត្តសញ្ញាណប័ណ្ណអ្នកបោះឆ្នោតរដ្ឋ California និងតម្រូវការចុះឈ្មោះ

## តើអ្នកណាអាចចុះឈ្មោះបោះឆ្នោតនៅរដ្ឋ California?

**ដើម្បីចុះឈ្មោះ អ្នកត្រូវតែ៖**

- ជាពលរដ្ឋសហរដ្ឋអាមេរិក និងជាអ្នករស់នៅក្នុងរដ្ឋ California
- មានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត (ឬមានអាយុ 16 ឬ 17 ឆ្នាំដើម្បីចុះឈ្មោះជាមុន)
- មិនកំពុងជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ
- មិនត្រូវបានតុលាការរកឃើញថាបាត់បង់សមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោតនោះទេ

## តើខ្ញុំត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណដើម្បីបោះឆ្នោតនៅរដ្ឋ California ទេ?

ក្នុងករណីភាគច្រើន មិនចាំបាច់ទេ California មិនតម្រូវឱ្យអ្នកបោះឆ្នោតបង្ហាញអត្តសញ្ញាណប័ណ្ណនៅកន្លែងបោះឆ្នោតនោះទេ។

## តើនៅពេលណាដែលអ្នកអាចត្រូវបានស្នើសុំឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណ?

អ្នកអាចនឹងត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណលុះត្រាតែលក្ខខណ្ឌខាងក្រោមទាំងអស់ត្រូវបានអនុវត្ត៖

- អ្នកជាអ្នកបោះឆ្នោតលើកដំបូងក្នុងការបោះឆ្នោតសហព័ន្ធ
- អ្នកបានចុះឈ្មោះតាមប្រៃសណីយ៍ ឬតាមអ៊ីនធឺណិតហើយ
- អ្នកមិនបានផ្តល់អត្តសញ្ញាណប័ណ្ណរដ្ឋ California ឬលេខ SSN របស់អ្នកនៅពេលចុះឈ្មោះ

អ្នកនឹងត្រូវបានជូនដំណឹងជាមុនប្រសិនបើលក្ខខណ្ឌនេះអនុវត្តចំពោះអ្នក។

**បុគ្គលិកបោះឆ្នោតអាចនឹងស្នើសុំអត្តសញ្ញាណប័ណ្ណបានលុះត្រាតែបញ្ជីឈ្មោះអ្នកបោះឆ្នោតបង្ហាញយ៉ាងច្បាស់ថាវាត្រូវបានទាមទារ។**

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ *vote.ca.gov* ឬហៅទូរសព្ទទៅខ្សែទូរសព្ទអ្នកបោះឆ្នោតរបស់យើងតាមលេខ (888) 345-4917។**

## តើអត្តសញ្ញាណប័ណ្ណប្រភេទណាខ្លះដែលត្រូវបានទទួលយក (ប្រសិនបើតម្រូវឱ្យមាន)?

**អ្នកអាចបង្ហាញអត្តសញ្ញាណប័ណ្ណដែលមានរូបថត ឬគ្មានរូបថត រួមទាំង៖**

- ប័ណ្ណបើកបររដ្ឋ California ឬអត្តសញ្ញាណប័ណ្ណរដ្ឋ
- លិខិតឆ្លងដែនអាមេរិក
- អត្តសញ្ញាណប័ណ្ណសិស្ស/និស្សិត ឬយោធា
- សំបុត្រផ្លូវការពីទីភ្នាក់ងាររដ្ឋាភិបាល
- មូលប្បទានប័ត្របើកប្រាក់បៀវត្សរ៍ ឬមូលប្បទានប័ត្ររដ្ឋាភិបាល
- វិក័យបត្រប្រើប្រាស់ ឬរបាយការណ៍ធនាគា

សម្រាប់បញ្ជីពេញលេញ សូមមើល៖ *www.sos.ca.gov/elections/hava-id-standards*

អត្តសញ្ញាណប័ណ្ណរូបថតមិនត្រូវបានទាមទារទេ វាគ្រាន់តែជាជម្រើសត្រឹមត្រូវមួយក្នុងចំណោមជម្រើសជាច្រើន។ អត្តសញ្ញាណប័ណ្ណមិនចាំបាច់ត្រូវបង្ហាញអាសយដ្ឋានរបស់អ្នក ឬចេញដោយរដ្ឋាភិបាលនោះទេ។

## មិនមានអត្តសញ្ញាណប័ណ្ណនៅពេលបោះឆ្នោតឬ?

អ្នកនៅតែអាចបោះឆ្នោតដោយសន្លឹកឆ្នោតបណ្តោះអាសន្នបាន។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បន្ទាប់ពីមន្ត្រីបោះឆ្នោតបានបញ្ជាក់ថាអ្នកបានចុះឈ្មោះបោះឆ្នោតនៅក្នុងខោនធីនោះ ហើយអ្នកមិនទាន់បានបោះឆ្នោតរួចរាល់ហើយនៅក្នុងការបោះឆ្នោតនោះទេ។

## ពិនិត្យស្ថានភាពអ្នកបោះឆ្នោតរបស់អ្នកតាមអ៊ីនធឺណិត

សូមចូលទៅកាន់ទំព័រស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំរបស់រដ្ឋលេខាធិការតាមរយៈ *voterstatus.sos.ca.gov* ដើម្បីពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ឬមណ្ឌលបោះឆ្នោត និងច្រើនទៀត។

ដើម្បីពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក អ្នកនឹងត្រូវបញ្ចូលឈ្មោះ នាមត្រកូល ថ្ងៃខែឆ្នាំកំណើត និងបណ្ណបើកបររដ្ឋ California ឬលេខអត្តសញ្ញាណបណ្ណរដ្ឋ California ឬលេខសន្តិសុខសង្គមរបស់អ្នកបួនខ្ទង់ចុងក្រោយ។

សូមចូលទៅកាន់ *voterstatus.sos.ca.gov* សម្រាប់ព័ត៌មានលម្អិតអំពីអ្នកបោះឆ្នោតសំខាន់ៗ។

# សិទ្ធិបោះឆ្នោតត្រូវបានជួយដល់បុគ្គលធ្លាប់ជាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋពីមុនបានដូចដើមវិញ

អ្នកអាចចុះឈ្មោះ រួចបោះឆ្នោតបាន ប្រសិនបើអ្នក៖

- ជាពលរដ្ឋ U.S. (អាមេរិក) និងជានិវាសនជននៃរដ្ឋ California
- មានអាយុ 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្នមិនត្រូវបានរកឃើញថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោតដោយតុលាការទេ
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ

ប្រសិនបើអ្នកបំពេញបានតាមលក្ខខណ្ឌតម្រូវទាំងនេះ អ្នកអាចបោះឆ្នោតបាន ថ្វីបើអ្នក៖

- ត្រូវមានការផ្តន្ទាទោសពីបទមជ្ឈិម (បទមជ្ឈិមនឹងមិនរារាំងអ្នកមិនឱ្យបោះឆ្នោត)
- ស្ថិតក្រោមការត្រួតពិនិត្យនៅក្រៅឃុំឬការការព្យួរទោសមានលក្ខខណ្ឌ
- ស្ថិតក្រោមការត្រួតពិនិត្យដោយសហគមន៍បន្ទាប់ពីដោះលែង (post-release community supervision, PRCS)

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វ៉ិបសាយថ៍ *votingrightsrestored.sos.ca.gov*។

## ចុះឈ្មោះ ឬចុះឈ្មោះឡើងវិញដើម្បីបោះឆ្នោតថ្ងៃនេះ!

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោត និងត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋទេ នោះការចុះឈ្មោះពីមុនរបស់អ្នកអាចត្រូវបានលុបចោល។

ចុះឈ្មោះ ឬចុះឈ្មោះឡើងវិញ ដើម្បីបោះឆ្នោតថ្ងៃនេះតាមអ៊ីនធឺណិតតាម *registertovote.ca.gov*។ អ្នកក៏អាចស្នើសុំបណ្ណចុះឈ្មោះអ្នកបោះឆ្នោតជាបណ្ណបានដែរ ដោយទូរសព្ទទៅលេខទូរសព្ទបន្ទាន់អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមរយៈ អ្នកក៏អាចស្នើសុំបណ្ណចុះឈ្មោះអ្នកបោះឆ្នោតជាបណ្ណបានដែរ ដោយទូរសព្ទទៅលេខទូរសព្ទបន្ទាន់អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការតាមរយៈ (888) 345-4917។

---

# ប្រជាធិបតេយ្យត្រូវការរូបអ្នក! បម្រើការជាបុគ្គលិកបោះឆ្នោត

ជួយសមាជិកសហគមន៍របស់អ្នកប្រើសិទ្ធិបោះឆ្នោតតាមរយៈការចុះឈ្មោះធ្វើជាអ្នកធ្វើការស្ម័គ្រចិត្ត។ ក្នុងនាមជាអ្នកធ្វើការស្ម័គ្រចិត្ត អ្នកអាចប្រាកដថាអ្នកបោះឆ្នោតអាចបោះឆ្នោតរបស់ខ្លួនបានយ៉ាងងាយស្រួល និងដោយសុវត្ថិភាព។ ទទួលបានបទពិសោធ និងចូលរួមក្នុងសិទ្ធិដ៏សំខាន់បំផុតតែមួយគត់នៅក្នុងលទ្ធិប្រជាធិបតេយ្យរបស់យើង ការបោះឆ្នោត! បំពេញទម្រង់បែបបទរបស់អ្នកនៅថ្ងៃនេះនៅតាមវ៉ិបសាយថ៍ *pollworker.sos.ca.gov*។

សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើជាបុគ្គលិកបោះឆ្នោត សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬទូរសព្ទទៅរដ្ឋលេខាធិការប្រចាំរដ្ឋ California តាម (888) 345-4917, ឬ ទស្សនាវ៉ិបសាយថ៍ *vote.ca.gov*។

# ជាអ្នកបោះឆ្នោតថ្មីមែនទេ? ចាប់ផ្តើមជាមួយជំហានងាយៗចំនួន 3!

## 1. ចុះឈ្មោះ!

- ចុះឈ្មោះបោះឆ្នោតត្រឹម **ថ្ងៃទី 20 ខែតុលា ឆ្នាំ 2025**។ ចុះឈ្មោះតាមអនឡាញតាមរយៈ *registertovote.ca.gov* ឬឱ្យផ្ញើទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោតតាមអ៊ីមែលទៅអ្នកតាមរយៈការហៅទូរសព្ទទៅខ្សែទូរសព្ទអ្នកបោះឆ្នោតដោយឥតគិតថ្លៃរបស់រដ្ឋលេខាធិការតាមលេខ (888) 345-4917។ ទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោតក៏មាននៅការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នក ការិយាល័យប្រៃសណីយ៍ក្នុងតំបន់ ឬបណ្ណាល័យផងដែរ។
- ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ ដែលគេស្គាល់ថាលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោតនៅក្នុងច្បាប់រដ្ឋ គឺជាបណ្តាញសុវត្ថិភាពសម្រាប់ពលរដ្ឋនៅរដ្ឋ California ដែលខកខានកាលបរិច្ឆេទកំណត់នៃការចុះឈ្មោះអ្នកបោះឆ្នោតថ្ងៃទី 20 ខែតុលា ឆ្នាំ 2025។ សូមចូលទៅកាន់ *vote.ca.gov* ឬមើលទំព័រទី 29 នៃមគ្គុទ្ទេសក៍នេះ ដើម្បីទទួលបានព័ត៌មានបន្ថែម។
- អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ប្រសិនបើអ្នកជាពលរដ្ឋអាមេរិក និងជាអ្នករស់នៅរដ្ឋ California ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត ហើយបច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសបទឧក្រិដ្ឋ និងបច្ចុប្បន្នមិនត្រូវបានរកឃើញថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោតដោយតុលាការទេ។

## 2. ទទួលបានការជូនដំណឹង!

- ក្នុងនាមជាអ្នកចុះឈ្មោះបោះឆ្នោត អ្នកនឹងទទួលបានធនធានព័ត៌មានចំនួនពីរនៅក្នុងសំបុត្រ៖
  - មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតនេះដែលមានព័ត៌មានអំពីវិធានការស្លឹកឆ្នោតទូទាំងរដ្ឋ ដំណើរការបោះឆ្នោត និងរបៀបបោះឆ្នោត។ ដើម្បីទទួលបានមគ្គុទ្ទេសក៍របស់អ្នកជាភាសាផ្សេង សូមហៅទូរសព្ទទៅលេខ (888) 345-4917 ឬចូលទៅកាន់ *voterguide.sos.ca.gov*។
  - ការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតខោនធីដែលមានសន្លឹកឆ្នោតគំរូ ទីតាំងកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតរបស់អ្នក និងព័ត៌មានមានប្រយោជន៍ផ្សេងទៀត។
- ព័ត៌មានអំពីការចំណាយ និងការចូលរួមវិភាគទានដល់យុទ្ធនាការថ្នាក់រដ្ឋពាក់ព័ន្ធនឹងបេក្ខជន និងវិធានការសន្លឹកឆ្នោតមាននៅ *sos.ca.gov/campaign-lobbying*។

## 3. បោះឆ្នោត!

- អ្នកអាចផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ៖



**តាមប្រអប់ទម្លាក់សន្លឹកឆ្នោត៖** អ្នកចុះឈ្មោះបោះឆ្នោតទាំងឡាយដែលសកម្មនៅរដ្ឋ California នឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍សម្រាប់ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូលថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ អ្នកអាចបញ្ជូនសន្លឹកឆ្នោតរបស់អ្នកទៅទីតាំងបោះឆ្នោត ឬទីតាំងទម្លាក់សន្លឹកឆ្នោតនៅរដ្ឋ California ត្រឹមម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត។



**ដោយផ្ទាល់៖** ទីតាំងបោះឆ្នោតត្រូវបានបង្កើតឡើងដោយមន្ត្រីរៀបចំការបោះឆ្នោតក្នុងខោនធី និងបើកចាប់ពីម៉ោង **7:00 ព្រឹក ដល់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត នៅថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025**។ ដើម្បីស្វែងរកទីតាំងបោះឆ្នោតជាមុន មុនថ្ងៃបោះឆ្នោត សូមចូលទៅកាន់ *caearlyvoting.sos.ca.gov*។

**តាមសំបុត្រ៖** សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ ដរាបណាអ្នកទទួលបានសំបុត្រនោះ។ សន្លឹកឆ្នោតផ្ញើតាមសំបុត្រត្រូវតែមានបោះត្រាប្រៃសណីយ៍មិនឱ្យលើសពីថ្ងៃបោះឆ្នោត និងទទួលបានមិនឱ្យលើសពីថ្ងៃទី 12 ខែវិច្ឆិកា ឆ្នាំ 2025។

**ជម្រើសសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព៖** ខោនធីផ្តល់នូវជម្រើសបោះឆ្នោតងាយស្រួលដែលមានឈ្មោះថាការបោះឆ្នោតតាមសំបុត្រងាយស្រួលពីចម្ងាយ (RAVBM)។ RAVBM អាចឱ្យអ្នកបោះឆ្នោតដែលមានពិការភាពទទួលបានសន្លឹកឆ្នោតរបស់ពួកគេនៅផ្ទះ ហើយគូសជ្រើសរើសដោយឯករាជ្យ និងជាឯកជន មុនពេលបញ្ជូនវាត្រឡប់ទៅមន្ត្រីរៀបចំការបោះឆ្នោតខោនធីរបស់ពួកគេ។

# អ្នកបោះឆ្នោតម៉ូតូរដ្ឋ California

កម្មវិធីអ្នកបោះឆ្នោតម៉ូតូរដ្ឋ California កំពុងធ្វើឱ្យការចុះឈ្មោះបោះឆ្នោតនៅនាយកដ្ឋានយានយន្តរដ្ឋ California (DMV) កាន់តែងាយស្រួល និងមានសុវត្ថិភាព។ បុគ្គលទាំងឡាយដែលមានសិទ្ធិមានបំពេញបណ្ណបើកបរ អត្តសញ្ញាណបណ្ណ ឬការផ្លាស់ប្តូរប្រតិបត្តិការអាសយដ្ឋានតាមអ៊ីនធឺណិត តាមប្រៃសណីយ៍ ឬដោយផ្ទាល់នៅ DMV នឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិដើម្បីបោះឆ្នោត លុះត្រាតែពួកគេជ្រើសរើស ‹‹ជ្រើសរើសយក›› ការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ។

កម្មវិធី អ្នកបោះឆ្នោតម៉ូតូរដ្ឋ California អនុវត្តចំពោះពលរដ្ឋ California មានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ហើយបំពេញតាមលក្ខណៈវិនិច្ឆ័យខាងក្រោមទាំងអស់៖

- ពលរដ្ឋអាមេរិក។
- រស់នៅរដ្ឋ California។
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ។
- បច្ចុប្បន្នមិនត្រូវបានរកឃើញថាអសមត្ថភាពផ្លូវចិត្ត ក្នុងការបោះឆ្នោតដោយតុលាការទេ។

ការចុះឈ្មោះជាមុនរបស់អ្នកបោះឆ្នោត សម្រាប់អ្នកមានអាយុ 16 និង 17 ឆ្នាំ។ ការចុះឈ្មោះបោះឆ្នោតរបស់ពួកគេនឹងក្លាយទៅជាសកម្មដោយស្វ័យប្រវត្តិនៅពេលពួកគេមានអាយុ 18 ឆ្នាំ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វ៉ិបសាយថ៍ *motorvoter.sos.ca.gov*។

ដើម្បីចុះឈ្មោះបោះឆ្នោតតាមអ៊ីនធឺណិត សូមចូលទៅកាន់វ៉ិបសាយថ៍ *registertovote.ca.gov*។

---

# ព័ត៌មានឯកជននៃការចុះឈ្មោះអ្នកបោះឆ្នោត

**កម្មវិធីចុះឈ្មោះសម្រាប់អ្នកបោះឆ្នោតសម្ងាត់នៅផ្ទះមានសុវត្ថិភាព៖** អ្នកបោះឆ្នោតមួយចំនួនដែលប្រឈមមុខនឹងស្ថានភាពគំរាមកំហែងដល់អាយុជីវិតអាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់ស្ថានភាពអ្នកបោះឆ្នោតសម្ងាត់ ប្រសិនបើពួកគេជាសមាជិកសកម្មនៃកម្មវិធីផ្ទះមានសុវត្ថិភាព។ នេះរួមបញ្ចូលជនរងគ្រោះ និងអ្នករស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ ការចាប់ជំរិត ការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស ការចាប់ជំរិតកុមារ និងការរំលោភបំពានលើមនុស្សចាស់/មនុស្សពេញវ័យនៅក្នុងបន្ទុក រួមទាំងនិយោជិត/អ្នកម៉ៅការនៃអង្គភាពសាធារណៈ ដែលភ័យខ្លាចពីសុវត្ថិភាពរបស់ខ្លួនដោយសារការងារនៅអង្គភាពសាធារណៈ ព្រមទាំងអ្នកផ្តល់សេវាថែទាំសុខភាពបន្តពូជ និយោជិត អ្នកស្ម័គ្រចិត្ត និងអ្នកជំងឺដែលភ័យខ្លាចពីសុវត្ថិភាពរបស់ខ្លួនដោយសារទំនាក់ទំនងរបស់ពួកគេជាមួយមន្ទីរថែទាំសុខភាពបន្តពូជ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់កម្មវិធីផ្ទះមានសុវត្ថិភាពរបស់រដ្ឋលេខាធិការដោយមិនគិតថ្លៃតាមលេខ (877) 322-5227 ឬចូលទៅកាន់ *sos.ca.gov/safeathome*។

**ភាពឯកជនព័ត៌មានស្តីពីអ្នកបោះឆ្នោត៖** ព័ត៌មានស្តីពីលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោតរបស់អ្នក នឹងត្រូវបានប្រើដោយមន្ត្រីរៀបចំការបោះឆ្នោត ដើម្បីផ្ញើជូនអ្នកនូវព័ត៌មានផ្លូវការស្តីអំពីដំណើរការបោះឆ្នោត ដូចជាទីតាំងបោះឆ្នោតរបស់អ្នក និងវិធានការ និងបេក្ខជនឈរឈ្មោះដែលនឹងបង្ហាញនៅលើសន្លឹកឆ្នោត។ ការប្រើប្រាស់ព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតជាលក្ខណៈពាណិជ្ជកម្ម ត្រូវបានហាមឃាត់ដោយច្បាប់ និងជាបទមជ្ឈិម។ ព័ត៌មានអ្នកបោះឆ្នោត អាចត្រូវបានផ្តល់ជូនដល់បេក្ខជនឈរឈ្មោះសម្រាប់ការិយាល័យ គណៈកម្មាធិការវាស់វែងសន្លឹកឆ្នោត ឬបុគ្គលផ្សេងទៀតសម្រាប់គោលបំណងបោះឆ្នោត អ្នករៀនសូត្រ សារព័ត៌មាន នយោបាយ ឬរដ្ឋាភិបាល ដូចដែលបានកំណត់ដោយ រដ្ឋលេខាធិការ។ ប័ណ្ណបើកបរ និងលេខសន្តិសុខសង្គម ឬហត្ថលេខារបស់អ្នក ដូចដែលបានបង្ហាញនៅលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក មិនអាចបញ្ចេញសម្រាប់ប្រើក្នុងគោលបំណងទាំងនេះបានទេ។ ប្រសិនបើអ្នកមានចម្ងល់ណាមួយអំពីការប្រើប្រាស់ព័ត៌មានអ្នកបោះឆ្នោត ឬចង់រាយការណ៍ដោយសង្ស័យថា មានការប្រើប្រាស់ព័ត៌មានខុសឆ្គង សូមទូរសព្ទទៅលេខទូរសព្ទទាន់ហេតុការណ៍អ្នកបោះឆ្នោត ដោយមិនគិតថ្លៃរបស់រដ្ឋលេខាធិការតាមរយៈ (888) 345-4917។

# ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព

រដ្ឋ California ប្តេជ្ញាធានាថាអ្នកបោះឆ្នោតគ្រប់រូបអាចបោះឆ្នោតដោយឯកជន និងឯករាជ្យ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីជំនួយដែលខោនធីរបស់អ្នកផ្តល់ជូនដល់អ្នកបោះឆ្នោតដែលមានពិការភាព សូមពិនិត្យមើលមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតខោនធីរបស់អ្នក ឬទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក។ ព័ត៌មានទំនាក់ទំនងតាមខោនធីមាននៅលើវិបសាយថ៍ *sos.ca.gov/elections/voting-resources/county-elections-offices*។

## បោះឆ្នោតនៅមណ្ឌលបោះឆ្នោត ឬមណ្ឌលបោះឆ្នោត

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការគូសសន្លឹកឆ្នោតរបស់អ្នក អ្នកអាចជ្រើសរើសបុគ្គលរហូតដល់ពីរនាក់ដើម្បីជួយអ្នក។ បុគ្គលនេះមិនអាចជា៖

- និយោជករបស់អ្នក ឬនរណាម្នាក់ដែលធ្វើការឱ្យនិយោជករបស់អ្នក
- ប្រធានសហជីពការងាររបស់អ្នក ឬក៏នរណាម្នាក់ដែលធ្វើការឱ្យសហជីពការងាររបស់អ្នក

*ការបោះឆ្នោតនៅខាងក្រៅ* អនុញ្ញាតឱ្យអ្នកចតបាននៅជិតកន្លែងបោះឆ្នោតតាមដែលអាចធ្វើទៅបាន។ មន្ត្រីរៀបចំការបោះឆ្នោតនឹងនាំមកជូនអ្នកនូវបញ្ជីឈ្មោះដើម្បីចុះហត្ថលេខា សន្លឹកឆ្នោត និងសម្ភារបោះឆ្នោតផ្សេងទៀតដែលអ្នកអាចត្រូវការ ទោះបីជាអ្នកពិតជានៅទីធ្លា ឬនៅក្នុងឡានក៏ដោយ។

កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោតទាំងអស់ តម្រូវឱ្យមានផ្លូវចូលសម្រាប់អ្នកបោះឆ្នោតដែលពិការ ហើយនឹងមានម៉ាស៊ីនបោះឆ្នោតដែលអាចចូលទៅដល់បាន។

## បោះឆ្នោតនៅផ្ទះ

ប្រព័ន្ធការបោះឆ្នោតពីចម្ងាយដោយផ្ញើតាមសំបុត្រ (RAVBM) សម្រាប់ អ្នកបោះឆ្នោតដែលមានពិការភាព ដើម្បីទទួលសន្លឹកឆ្នោតនៅផ្ទះ ហើយសម្គាល់ដោយឯករាជ្យ និងឯកជន មុននឹងបញ្ជូនទៅមន្ត្រីរៀបចំការបោះឆ្នោតវិញ។ ទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

## មគ្គុទ្ទេសក៍ព័ត៌មានសម្រាប់អ្នកបោះឆ្នោតជាសំឡេង និងអក្សរធំ

មគ្គុទ្ទេសក៍នេះមានជាសំឡេង និងកំណែអក្សរធំ ព្រមទាំងជាភាសាអង់គ្លេស ចិន ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាកាឡុក ថៃ និងវៀតណាមដោយមិនគិតថ្លៃ។

ដើម្បីបញ្ជាទិញ៖

ចូលទៅកាន់ *vote.ca.gov*

អ្នកក៏អាចចូលទៅកាន់វិបសាយថ៍របស់រដ្ឋលេខាធិការនៅតាម vote.ca.gov ឬហៅទូរសព្ទទៅលេខទូរសព្ទអ្នកបោះឆ្នោតដោយមិនគិតថ្លៃតាមលេខ (888) 345-4917

ទាញយកកំណែសំឡេង MP3 តាមរយៈ *voterguide.sos.ca.gov/kh/audio*

# ការិយាល័យបោះឆ្នោតប្រចាំខោនធី

**ខោនធី Alameda**
(800) 834-6454
*www.acvote.org*

**ខោនធី Alpine**
(530) 694-2281
*www.alpinecountyca.gov/*

**ខោនធី Amador**
(209) 223-6465
*www.amadorgov.org/government/elections*

**ខោនធី Butte**
(530) 552-3400 or (800) 894-7761
(នៅក្នុងខោនធី Butte)
*www.buttevotes.net*

**ខោនធី Calaveras**
(209) 754-6376 ឬ (833) 536-8683
*www.calaverasgov.us/*

**ខោនធី Colusa**
(530) 458-0500 ឬ (877) 458-0501
*www.countyofcolusa.org/elections*

**ខោនធី Contra Costa**
(925) 335-7800
*www.contracostavote.gov/elections/*

**ខោនធី Del Norte**
(707) 464-7216
*www.co.del-norte.ca.us/departments/Elections*

**ខោនធី El Dorado**
(530) 621-7480
*www.edcgov.us/Government/Elections*

**ខោនធី Fresno**
(559) 600-8683
*www.fresnovote.com*

**ខោនធី Glenn**
(530) 934-6414
*www.countyofglenn.net/dept/elections*

**ខោនធី Humboldt**
(707) 445-7481
*www.humboldtgov.org/Elections*

**ខោនធី Imperial**
(442) 265-1060
*www.elections.imperialcounty.org*

**ខោនធី Inyo**
(760) 878-0224
*elections.inyocounty.us/*

**ខោនធី Kern**
(661) 868-3590 ឬ (800) 452-8683
*www.kernvote.com*

**ខោនធី Kings**
(559) 852-4401 ឬ
(800) 289-9981 ext. 4401
*www.votekingscounty.com*

**ខោនធី Lake**
(707) 263-2372 ឬ (888) 235-6730
*www.lakecountyca.gov/818/Registrar-of-Voters*

**ខោនធី Lassen**
(530) 251-8217
*www.lassencounty.org/dept/county-clerk-recorder/elections*

**ខោនធី Los Angeles**
(800) 815-2666
*www.lavote.gov/home/voting-elections*

**ខោនធី Madera**
(559) 675-7720 ឬ (800) 435-0509
*www.votemadera.com*

**ខោនធី Marin**
(415) 473-6456
*www.marinvotes.org*

**ខោនធី Mariposa**
(209) 966-2007
*www.mariposacounty.org/87/Elections*

**ខោនធី Mendocino**
(707) 234-6819
*www.mendocinocounty.gov/government/assessor-county-clerk-recorder-elections/elections*

**ខោនធី Merced**
(209) 385-7541 ឬ (800) 561-0619
*www.mercedelections.org*

**ខោនធី Modoc**
(530) 233-6200
*www.co.modoc.ca.us/departments/elections/*

**ខោនធី Mono**
(760) 932-5537 ឬ (760) 932-5530
*monocounty.ca.gov/elections*

**ខោនធី Monterey**
(831) 796-1499 ឬ (866) 887-9274
*www.montereycountyelections.us/*

**ខោនធី Napa**
(707) 253-4321
*www.countyofnapa.org/396/elections*

**ខោនធី Nevada**
(530) 265-1298 ឬ (888) 395-1298
*www.nevadacountyca.gov/1847/Elections-Voting*

**ខោនធី Orange**
(714) 567-7600 ឬ (888) 628-6837
*www.ocvote.com*

**ខោនធី Placer**
(530) 886-5650 ឬ (800) 824-8683
*www.placercountyelections.gov*

**ខោនធី Plumas**
(530) 283-6256 ឬ (844) 676-VOTE
*www.plumascounty.us/142/Elections-Division-Home*

**ខោនធី Riverside**
(951) 486-7200
*www.voteinfo.net*

**ខោនធី Sacramento**
(916) 875-6451 ឬ (800) 762-8019
*www.elections.saccounty.gov*

**ខោនធី San Benito**
(831) 636-4016
*www.sanbenitocounty-ca-cre.gov/elections*

**ខោនធី San Bernardino**
(909) 387-8300
*www.sbcountyelections.com*

**ខោនធី San Diego**
(858) 565-5800 ឬ (800) 696-0136
*www.sdvote.com/*

**ខោនធី San Francisco**
(415) 554-4375
*sfelections.sfgov.org*

**ខោនធី San Joaquin**
(209) 468-2890 ឬ (209) 468-8683
*www.sjcrov.org*

**ខោនធី San Luis Obispo**
(800) 834-4636
*www.slovote.com*

**ខោនធី San Mateo**
(650) 312-5222
*www.smcacre.org*

**ខោនធី Santa Barbara**
(805) 568-2200 ឬ (800) 722-8683
*www.sbcvote.com*

**ខោនធី Santa Clara**
(408) 299-8683 ឬ (866) 430-8683
*www.sccvote.org*

**ខោនធី Santa Cruz**
(831) 454-2060 ឬ (866) 282-5900
*www.votescount.com*

**ខោនធី Shasta**
(530) 225-5730
*www.elections.shastacounty.gov*

**ខោនធី Sierra**
(530) 289-3295
*www.sierracounty.ca.gov/214/Elections*

**ខោនធី Siskiyou**
(530) 842-8084
*www.co.siskiyou.ca.us/elections*

**ខោនធី Solano**
(707) 784-6675 ឬ (888) 933-8683
*www.solanocounty.com/elections*

**ខោនធី Sonoma**
(707) 565-6800 ឬ (800) 750-8683
*vote.sonoma-county.org*

**ខោនធី Stanislaus**
(209) 525-5200 ឬ (833) 772-2260
*www.stanvote.com*

**ខោនធី Sutter**
(530) 822-7122
*www.suttercounty.org/elections*

**ខោនធី Tehama**
(530) 527-8190
*www.co.tehama.ca.us/government/departments/elections/*

**ខោនធី Trinity**
(530) 623-1220
*www.trinitycounty.org/214/Elections*

**ខោនធី Tulare**
(559) 839-2100
*tularecoelections.org/elections/*

**ខោនធី Tuolumne**
(209) 533-5570
*www.co.tuolumne.ca.us/elections*

**ខោនធី Ventura**
(805) 654-2664
*www.venturavote.org*

**ខោនធី Yolo**
(530) 666-8133
*www.yoloelections.org*

**ខោនធី Yuba**
(530) 749-7855
*www.yubaelections.org*

# ពិនិត្យស្ថានភាពអ្នកបោះឆ្នោតរបស់អ្នកតាមអ៊ីនធឺណិត

**ស្ថានភាព**
**អ្នកបោះឆ្នោតរបស់ខ្ញុំ**

សូមចូលទៅកាន់ទំព័រស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំរបស់រដ្ឋលេខាធិការតាមរយៈ *voterstatus.sos.ca.gov* ដើម្បីពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ឬមណ្ឌលបោះឆ្នោត និងច្រើនទៀត។

ដើម្បីពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក អ្នកនឹងត្រូវបញ្ចូលឈ្មោះ នាមត្រកូល ថ្ងៃខែឆ្នាំកំណើត និងបណ្ណបើកបររដ្ឋ California ឬលេខអត្តសញ្ញាណបណ្ណរដ្ឋ California ឬលេខសន្តិសុខសង្គមរបស់អ្នកបួនខ្ទង់ចុងក្រោយ។

សូមចូលទៅកាន់ *voterstatus.sos.ca.gov* សម្រាប់ព័ត៌មានលម្អិតអំពីអ្នកបោះឆ្នោតសំខាន់ៗ។

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំភ្លេចចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់ខ្ញុំ?

គ្មានបញ្ហាទេ! ប្រសិនបើអ្នកខកខានកាលបរិច្ឆេទចុះឈ្មោះអ្នកបោះឆ្នោតថ្ងៃទី 20 ខែតុលា ឆ្នាំ 2025 ច្បាប់រដ្ឋ California អនុញ្ញាតឱ្យអ្នកចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតរហូតដល់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោតនៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬនៅទីតាំងបោះឆ្នោតណាមួយនៅក្នុងខោនធីរបស់អ្នក។ ដំណើរការនេះហៅថាលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត (CVR) និងជាទូទៅហៅថាការចុះឈ្មោះបោះឆ្នោតនៅថ្ងៃតែមួយ។

# ការបោះឆ្នោតបណ្ដោះអាសន្ន

## មិនមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតនៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតមែនទេ?

អ្នកនៅតែមានសិទ្ធិបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។

## តើសន្លឹកឆ្នោតបណ្ដោះអាសន្នគឺជាអ្វី?

សន្លឹកឆ្នោតបណ្ដោះអាសន្ន គឺជាសន្លឹកឆ្នោតធម្មតាដែលដាក់ក្នុងស្រោមសំបុត្រពិសេស មុននឹងដាក់ក្នុងប្រអប់សន្លឹកឆ្នោត។ សន្លឹកឆ្នោតបណ្ដោះអាសន្ន គឺជាសន្លឹកឆ្នោតដែលបោះដោយអ្នកបោះឆ្នោតដែលជឿថាពួកគេបានចុះឈ្មោះបោះឆ្នោត ទោះបីជាឈ្មោះរបស់ពួកគេមិនមាននៅក្នុងបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតផ្លូវការនៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោត។

អ្នកបោះឆ្នោតអាចនឹងត្រូវបោះឆ្នោតបណ្ដោះអាសន្ន ប្រសិនបើពួកគេចង់បោះឆ្នោតដោយផ្ទាល់នៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោត ប៉ុន្តែមិនបានទទួលសន្លឹកឆ្នោតផ្ញើតាមសំបុត្រ ឬប្រសិនបើពួកគេមិនមានសន្លឹកឆ្នោតផ្ញើតាមសំបុត្រជាមួយពួកគេក្នុងការប្រគល់មុនពេលបោះឆ្នោតដោយផ្ទាល់។

## តើសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់ខ្ញុំនឹងត្រូវបានរាប់ដែរឬទេ?

បាទ/ចាស សន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកនឹងត្រូវបានរាប់បន្ទាប់ពីមន្ត្រីរៀបចំការបោះឆ្នោតបានបញ្ជាក់ថា អ្នកបានចុះឈ្មោះបោះឆ្នោតនៅក្នុងខោនធីនោះ ហើយអ្នកមិនបានបោះឆ្នោតរួចហើយនៅក្នុងការបោះឆ្នោតនោះទេ។

សន្លឹកឆ្នោតបណ្ដោះអាសន្នអាចត្រូវបានប្រើប្រាស់នៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ មានតែការប្រកួតប្រជែងការបោះឆ្នោត ដែលអ្នកមានសិទ្ធិបោះឆ្នោតប៉ុណ្ណោះនឹងត្រូវបានរាប់។

## តើអ្នកអាចពិនិត្យស្ថានភាពសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកដោយរបៀបណា?

អ្នកណាដែលបោះឆ្នោតបណ្ដោះអាសន្ន មានសិទ្ធិស្វែងយល់ពីមន្ត្រីរៀបចំការបោះឆ្នោតខោនធីរបស់ខ្លួន ប្រសិនបើសន្លឹកឆ្នោតត្រូវបានរាប់ ហើយបើមិនរាប់ទេ មូលហេតុមិនត្រូវបានរាប់។

អ្នកអាចពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នកតាមរយៈ *voterstatus.sos.ca.gov*។

# របៀបដោះស្រាយហត្ថលេខាដែលបាត់ ឬខុសគ្នានៅក្នុងស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់អ្នក

## បញ្ហាដែលអាចមានជាមួយស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតផ្ញើតាមសំបុត្រ ឬសន្លឹកឆ្នោតបណ្ដោះអាសន្ន

- **ហត្ថលេខាដែលបាត់៖** អ្នកភ្លេចចុះហត្ថលេខាលើស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់អ្នក។
- **ហត្ថលេខាមិនដូចគ្នា៖** ហត្ថលេខារបស់អ្នកមិនដូចគ្នានឹងហត្ថលេខានៅលើឯកសារដែលមាននៅមន្ត្រីរៀបចំការបោះឆ្នោត។

## តើមានអ្វីកើតឡើងបន្ទាប់?

- **ការជូនដំណឹង៖** ប្រសិនបើមានបញ្ហាជាមួយសន្លឹកឆ្នោតរបស់អ្នក ការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នកនឹងជូនដំណឹងអ្នកតាមសំបុត្រ ទូរសព្ទ អ៊ីមែល ឬពីឧបករណ៍ ***សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?*** របស់រដ្ឋលេខាធិការ។
- **របៀបដោះស្រាយបញ្ហានេះ៖** អ្នកអាចចូលប្រើទម្រង់បែបបទនៅលើគេហទំព័ររបស់មន្ត្រីរៀបចំការបោះឆ្នោតក្នុងខោនធីរបស់អ្នក ដើម្បីផ្តល់ហត្ថលេខារបស់អ្នក និងបញ្ជាក់ថាអ្នកបានបោះឆ្នោត។
  - ពិនិត្យមើលសំបុត្រ ឬអ៊ីមែលសម្រាប់ការណែនាំពីការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នក
  - បំពេញទម្រង់បែបបទ និងអនុវត្តតាមការណែនាំអំពីរបៀបផ្ញើទម្រង់បែបបទត្រឡប់មកវិញ
  - ជម្រើសផ្ញើទម្រង់បែបបទត្រឡប់មកវិញរបស់អ្នកអាចប្រែប្រួលទៅតាមខោនធី
  - ការខកខានអនុវត្តតាមការណែនាំអាចបណ្តាលឱ្យសន្លឹកឆ្នោតរបស់អ្នកមិនត្រូវបានរាប់

## បន្តតាមដានជាមួយ *សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?*

- **តាមដានសន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់អ្នក៖** ទទួលបានព័ត៌មានថ្មីៗដោយស្វ័យប្រវត្តិអំពីស្ថានភាពសន្លឹកឆ្នោតរបស់អ្នកដោយចុះឈ្មោះប្រើ ***សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?***
- ទទួលបានការជូនដំណឹងតាមរយៈ**សារជាអក្សរ អ៊ីមែល ឬទូរសព្ទ**ពាក់ព័ន្ធនឹង៖
  - ពេលវេលាផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍
  - ពេលវេលាទទួលបានសន្លឹកឆ្នោត
  - ថាតើសន្លឹកឆ្នោតត្រូវបានរាប់ឬអត់
  - ប្រសិនបើមានបញ្ហាដែលចាំបាច់ត្រូវដោះស្រាយ
- **សូមចុះឈ្មោះប្រើនៅថ្ងៃនេះតាមរយៈ៖ *wheresmyballot.sos.ca.gov***

## កាលបរិច្ឆេទកំណត់សំខាន់ៗសម្រាប់ការបោះឆ្នោតពិសេសទូទាំងរដ្ឋនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025៖

- **សន្លឹកឆ្នោតផ្ញើតាមសំបុត្រ៖** សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ ដរាបណាអ្នកទទួលបានសំបុត្រនោះ។ ត្រូវតែមានបោះត្រាប្រៃសណីយ៍មិនឱ្យលើសពី**ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025** និងទទួលបានមិនឱ្យលើស**ពីថ្ងៃទី 12 ខែវិច្ឆិកា ឆ្នាំ 2025។**
- **កាលបរិច្ឆេទកំណត់៖** កាលបរិច្ឆេទកំណត់ដើម្បីដោះស្រាយហត្ថលេខាដែលបាត់ ឬមិនដូចគ្នារបស់អ្នក គឺ 5:00 ល្ងាច នៅថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2025 ពីរថ្ងៃមុនថ្ងៃដែលខោនធីរបស់អ្នកបញ្ជាក់ការបោះឆ្នោត។

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ *vote.ca.gov* ឬហៅទូរសព្ទទៅខ្សែទូរសព្ទអ្នកបោះឆ្នោតរបស់យើងតាមលេខ (888) 345-4917។**

# កាលបរិច្ឆេទដែលត្រូវចងចាំ!



## កុំពន្យារពេល សូមបោះឆ្នោតនៅថ្ងៃនេះ!

**រយៈពេលបោះឆ្នោតតាមសំបុត្រជាមុនគឺចាប់ពីថ្ងៃទី 6 ខែតុលា ដល់ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។**

**ការបោះឆ្នោតចាប់បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025 ជាថ្ងៃបោះឆ្នោត!**

### ខែតុលា

| S | M | T | W | T | F | S |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | 31 | |

**ថ្ងៃទី 6 ខែតុលា**
មន្ត្រីរៀបចំការបោះឆ្នោតខោនធីនឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតផ្ញើតាមសំបុត្រនៅ ឬមុនកាលបរិច្ឆេទនេះ។

**ថ្ងៃទី 6 ខែតុលា–ថ្ងៃទី 4 ខែវិច្ឆិកា**
រយៈពេលបោះឆ្នោត ដែលត្រូវផ្ញើសន្លឹកឆ្នោតតាមសំបុត្រមកវិញ។

**ថ្ងៃទី 7 ខែតុលា**
ប្រអប់ទម្លាក់សុវត្ថិភាពបោះឆ្នោតតាមសំបុត្របើកចំហ។

**ថ្ងៃទី 20 ខែតុលា**
ថ្ងៃចុងក្រោយក្នុងការចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយមាននៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬទីតាំងបោះឆ្នោតក្រោយពីថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោត រហូតដល់ និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោត។

**ថ្ងៃទី 25 ខែតុលា**
មណ្ឌលបោះឆ្នោតថ្ងៃដំបូងបើកនៅក្នុងខោនធីទាំងអស់តាមច្បាប់នៃជម្រើសអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតដោយផ្ទាល់មុនកាលកំណត់។

### វិច្ឆិកា

| S | M | T | W | T | F | S |
|---|---|---|---|---|---|---|
| | | | | | | 1 |
| 2 | 3 | 4 | 5 | 6 | 7 | 8 |
| 9 | 10 | 11 | 12 | 13 | 14 | 15 |
| 16 | 17 | 18 | 19 | 20 | 21 | 22 |
| 23 | 24 | 25 | 26 | 27 | 28 | 29 |
| 30 | | | | | | |

**ថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025**
ថ្ងៃចុងក្រោយដើម្បីបោះឆ្នោតដោយផ្ទាល់ ឬផ្ញើសន្លឹកឆ្នោតតាមសំបុត្រនៅត្រឹមម៉ោង 8:00 យប់។

ការបោះឆ្នោតចាប់បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់។

សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រដរាបណាអ្នកទទួលបានសំបុត្រនោះ។ សន្លឹកឆ្នោតផ្ញើតាមសំបុត្រត្រូវដាក់ស្លាកប្រៃសណីយ៍មិនឱ្យលើសពីថ្ងៃទី 4 ខែវិច្ឆិកា។

**California Secretary of State**
**Elections Division**
1500 11th Street
Sacramento, CA 95814

NONPROFIT
U.S. POSTAGE
PAID
CALIFORNIA
SECRETARY
OF STATE

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025

# ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូល

## កាលបរិច្ឆេទដែលត្រូវចងចាំ

### ថ្ងៃទី 6 ខែតុលា

មន្ត្រីរៀបចំការបោះឆ្នោតខោនធីនឹងចាប់ផ្ដើមផ្ញើសន្លឹកឆ្នោតផ្ញើតាមសំបុត្រនៅ ឬមុនកាលបរិច្ឆេទនេះ។

### ថ្ងៃទី 6 ខែតុលា – ថ្ងៃទី 4 ខែវិច្ឆិកា

រយៈពេលបោះឆ្នោត ដែលត្រូវផ្ញើសន្លឹកឆ្នោតតាមសំបុត្រមកវិញ។

### ថ្ងៃទី 7 ខែតុលា

ប្រអប់ទម្លាក់សុវត្ថិភាពបោះឆ្នោតតាមសំបុត្របើកចំហ។

### ថ្ងៃទី 20 ខែតុលា

ថ្ងៃចុងក្រោយក្នុងការចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយមាននៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬទីតាំងបោះឆ្នោតក្រោយពីថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោត រហូតដល់ និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោត។

### ថ្ងៃទី 25 ខែតុលា

មណ្ឌលបោះឆ្នោតថ្ងៃដំបូងបើកនៅក្នុង ច្បាប់នៃជម្រើសរបស់អ្នកបោះឆ្នោតខោនធីសម្រាប់ការបោះឆ្នោតដោយផ្ទាល់មុនកាលកំណត់។

### ថ្ងៃអង្គារ ទី 4 ខែវិច្ឆិកា ឆ្នាំ 2025

ថ្ងៃចុងក្រោយដើម្បីបោះឆ្នោតដោយផ្ទាល់ ឬផ្ញើ សន្លឹកឆ្នោត តាមសំបុត្រនៅត្រឹមម៉ោង 8:00 យប់។ ការបោះឆ្នោតចាប់បើកពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់។ សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រដរាបណាអ្នកទទួលបានសំបុត្រនោះ។ សន្លឹកឆ្នោតផ្ញើតាមសំបុត្រត្រូវដាក់ស្លាកប្រៃសណីយ៍មិនឱ្យលើសពីថ្ងៃទី 4 ខែវិច្ឆិកា។

## សម្រាប់ច្បាប់ចម្លងបន្ថែមស្ដីពីមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតជាភាសាណាមួយខាងក្រោម សូមហៅទូរសព្ទទៅ៖

**English:** (800) 345-VOTE (8683)

**Español/Spanish:** (800) 232-VOTA (8682)

中文/**Chinese:** (800) 339-2857

हिन्दी/**Hindi:** (888) 345-2692

日本語/**Japanese:** (800) 339-2865

ខ្មែរ/**Khmer:** (888) 345-4917

한국어/**Korean:** (866) 575-1558

**Tagalog:** (800) 339-2957

ภาษาไทย/**Thai:** (855) 345-3933

Việt ngữ/**Vietnamese:** (800) 339-8163

**TTY/TDD:** 711

ប្រើតាមទូរសព្ទចល័តបាន ស្កេនខ្ញុំ

**តើអ្នកបានចុះឈ្មោះឬនៅ? សូមពិនិត្យមើលតាម៖ *voterstatus.sos.ca.gov***

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការចំណាយលើការបោះឆ្នោត ស្ថាប័ននីតិប្បញ្ញត្តិរបស់រដ្ឋបានអនុញ្ញាតឲ្យរដ្ឋ និងខោនធីផ្ញើសៀវភៅណែនាំតែមួយគត់ទៅកាន់គ្រួសារកំពុងបោះឆ្នោតនីមួយៗ។ អ្នកអាចស្នើសុំច្បាប់ចម្លងបន្ថែមដោយទាក់ទងទៅមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក ឬដោយទូរសព្ទទៅលេខ (888) 345-4917។



OSP 25 160209